កំណែដែលបានកែសម្រួលជាមុន

ចែកចាយ៖ ទូទៅ
១២ កញ្ញា ២០២៥

ឯកសារដើម ៖ ភាសាអង់គ្លេស

# ក្រុមប្រឹក្សាសិទ្ធិមនុស្ស

**សម័យប្រជុំលើកទីហុកសិប**

ថ្ងៃទី៨ ខែកញ្ញា ដល់ថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥

របៀបវារៈចំណុចទី២ និងទី១០

**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យ ឧត្តមស្នងការ និងអគ្គលេខាធិការ**

**ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព**

## តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការគាំទ្រដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ និង ការពារសិទ្ធិមនុស្ស

**របាយការណ៍របស់អគ្គលេខាធិការ***


*សេចក្តីសង្ខេប*

ដាក់ជូនស្របតាមសេចក្តីសម្រេចលេខ 54/36 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍បច្ចុប្បន្ននេះ បង្ហាញពីតួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជា ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២៤ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥។

ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ការិយាល័យ OHCHR បានបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួងនានារបស់រដ្ឋាភិបាល គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ក្រុមប្រឹក្សាសកម្មភាពជនពិការ និងស្ថាប័នរដ្ឋាភិបាលដទៃទៀត ដើម្បីផ្តល់ជំនួយបច្ចេកទេស និងមតិយោបល់។ ការិយាល័យ OHCHR ក៏បានរៀបចំការកសាងសមត្ថភាពសម្រាប់តួអង្គសង្គមស៊ីវិលរួមទាំង ដើម្បីពង្រឹងតួនាទីរបស់សង្គមស៊ីវិល ក្នុងការចូលរួមជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិ និងការជំរុញសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ របាយការណ៍នេះ រំលេចពីការរឹតបន្តឹងចំពោះលំហាពលរដ្ឋ និងសិទ្ធិចូលរួមកិច្ចការសាធារណៈ ក្នុងចំណោមសិទ្ធិផ្សេងៗទៀត។


* របាយការណ៍បច្ចុប្បន្ននេះ ត្រូវបានដាក់ជូនទៅផ្នែកសេវាសន្និសីទ ដើម្បីដំណើរការ បន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ចំពោះហេតុផលបច្ចេកទេស ហួសពីការគ្រប់គ្រងរបស់ការិយាល័យដែលបានដាក់ជូនរបាយការណ៍។

## I. សេចក្តីផ្តើម

1. នៅក្នុងរបាយការណ៍បច្ចុប្បន្ន ដែលត្រូវបានដាក់ជូន ស្របតាមសេចក្តីសម្រេចលេខ 54/36 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អគ្គលេខាធិការ បង្ហាញពីតួនាទី និងសមិទ្ធផល របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្នុងការគាំទ្រដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥។

2. ការិយាល័យ OHCHR បានផ្តល់ជំនួយបច្ចេកទេសដល់ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គណៈកម្មាធិការជាតិប្រឆាំងការធ្វើទារុណកម្ម ក្រុមប្រឹក្សាសកម្មភាពជនពិការ និងមូលនិធិជាតិជំនួយសង្គម។

3. ការិយាល័យ OHCHR បានបន្តតាមដានស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដោយអនុលោមតាមវិធីសាស្ត្ររបស់ខ្លួន។[1] ការិយាល័យ OHCHR បានគាំទ្រដល់ក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេស ដើម្បីបញ្ជ្រាបសិទ្ធិមនុស្សទៅក្នុងក្របខណ្ឌកម្មវិធីជាតិនានា និងក្របខណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ សម្រាប់កម្ពុជា ឆ្នាំ២០២៤-២០២៨ ។

4. ការិយាល័យ OHCHR ក៏បានបន្តគាំទ្ររដ្ឋាភិបាល ដើម្បីធ្វើឱ្យមានវឌ្ឍនភាពឆ្ពោះទៅការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និងអនុសាសន៍នានា ដែលទទួលបានពីយន្តការសិទ្ធិមនុស្សអន្តរជាតិ។ លើសពីនេះ ការិយាល័យ OHCHR បានផ្តល់មតិយោបល់លើការផ្តួចផ្តើមធ្វើច្បាប់ រួមមាន សេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារសិទ្ធិជនមានពិការភាព ព្រះរាជក្រឹត្យពាក់ព័ន្ធនឹងអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

## II. បរិបទ

5. ការងាររបស់ការិយាល័យ OHCHR នៅកម្ពុជា បានបន្ត នៅក្នុងបរិបទមួយ ដែលមានទាំងវឌ្ឍនភាព និងបញ្ហាប្រឈម។ ខណៈដែលសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញក្រោយពីការរាតត្បាតនៃជំងឺកូវីដ-១៩ (COVID-19) បានបន្តស្ថិតក្នុងគន្លងវិជ្ជមានក្តី មានការបារម្ភកាន់តែខ្លាំងអំពីការរួមតូចនៃលំហពលរដ្ឋ ដែលជួនកាលក៏បានកើតឡើងជាលក្ខណៈឆ្លងដែនផងដែរ។

6. ក្នុងអំឡុងពេលនៃរបាយការណ៍នេះ មានការរឹតត្បិតលំហពលរដ្ឋ ជាពិសេសពាក់ព័ន្ធនឹងអ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាបរិស្ថាន ក៏ដូចជារាយការណ៍អំពីតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ-វៀតណាម។ បន្ទាប់ពីសន្និសីទសារព័ត៌មានមួយ កាលពីខែកក្កដា ឆ្នាំ២០២៤ ដែលនៅពេលនោះ លោក ហ៊ុន សែន ប្រធានព្រឹទ្ធសភា បានបញ្ជាឱ្យអាជ្ញាធរស្វែងរក និងចាត់វិធានការខ្លាំងលើការរិះគន់ទាំងអស់ស្តីពីតំបន់ត្រីកោណអភិវឌ្ឍន៍ អាជ្ញាធរបានដាក់វិធានការរឹតត្បិតហួសហេតុចំពោះសេរីភាពខាងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី និងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិមនុស្សផ្សេងទៀត។ មានការរាយការណ៍ថាយ៉ាងហោចណាស់មនុស្ស ចំនួន ៦៨នាក់ ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងការគ្រោងធ្វើបាតុកម្មទាក់ទងនឹងតំបន់ត្រីកោណអភិវឌ្ឍន៍ ក្នុងខែសីហា ឆ្នាំ២០២៤។ មនុស្ស ៧ នាក់ក៏ត្រូវបានចាប់បញ្ជូនដោយបង្ខំពីប្រទេសថៃមកកម្ពុជាវិញ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ហើយត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌចំពោះការបញ្ចេញមតិ តាមប្រព័ន្ធផ្សព្វផ្សាយសង្គមទាក់ទងនឹងតំបន់ត្រីកោណអភិវឌ្ឍន៍។ ការចាប់

[1] សូមមើល www.ohchr.org/en/publications/policy-and-methodological-publications/manual-human rightsmonitoring-revised-edition។

បញ្ជូនត្រឡប់មកប្រទេសវិញនេះ ជាផ្នែកមួយនៃនិន្នាការគាបសង្កត់ឆ្លងដែនដែលកំពុងលេចរូបរាងឡើង[2] នៅអាស៊ីអាគ្នេយ៍[3]។

## III. សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

### ក. ម៉ាក្រូសេដ្ឋកិច្ច និងការបែងចែកថវិកា

7. ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាក្រោយជំងឺកូវីដ-១៩ បានបន្តនៅលើគន្លងវិជ្ជមាន ដែលជំរុញដោយការងើបឡើងវិញនៃការនាំចេញសម្លៀកបំពាក់ ផលិតផលធ្វើដំណើរ និងស្បែកជើង រួមជាមួយនឹងការងើបឡើងវិញជាលំដាប់នៃវិស័យទេសចរណ៍។[4] ឧស្សាហកម្មទាំងនេះបានគាំទ្រដល់សន្ទុះសេដ្ឋកិច្ច ដែលរួមចំណែកដល់កំណើនផលិតផលក្នុងស្រុកសរុប (GDP) ប្រមាណ ៥,៥ ភាគរយ នៅឆ្នាំ២០២៤ ជាមួយនឹងការព្យាករណ៍ដែលបង្ហាញពីការកើនឡើងបន្ថែមទៀតរហូតដល់ ៥,៨ ភាគរយ នៅឆ្នាំ២០២៥។[5]

8. អត្រាអតិផរណាជាមធ្យមក្នុងឆ្នាំ២០២៤ មានកម្រិត ០,៧៩ ភាគរយ ដែលធ្លាក់ចុះ ១,៣៥ ភាគរយ ធៀបនឹងឆ្នាំមុន។[6] ទោះជាយ៉ាងនេះក្តី ចំណូលសរុបរបស់រដ្ឋាភិបាល រួមទាំងចំណូលថ្នាក់ក្រោមជាតិផងបានធ្លាក់ចុះជិត ១៦ ភាគរយ[7] ដែលអាចប៉ះពាល់ដល់ធនធានទាំងឡាយដែលមាន ដើម្បីពង្រីកការវិនិយោគសាធារណៈ និងការផ្តល់សេវាសំខាន់ៗនានា។

9. យោងតាមតួលេខរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថា បំណុលសាធារណៈកម្ពុជានៅតែមានស្ថិរភាពខ្លាំង។ សេវាបំណុលពីខាងក្រៅនៅតែអាចគ្រប់គ្រងបាន ដោយកម្ពុជាបានបែងចែកថវិកា ៧,៨ ភាគរយ នៃចំណូលរបស់ប្រទេសទៅក្នុងបំណុលពីខាងក្រៅនេះ ក្នុងឆ្នាំ២០២៤ ដែលតួលេខនេះ បានកើនឡើងពី ៧,៥ ភាគរយនៅឆ្នាំ ២០២៣។ នៅឆ្នាំ ២០២៤ កម្ពុជាបានបន្តជាប់ចំណាត់ថ្នាក់ជាប្រទេសដែលមានភាពតានតឹងផ្នែកបំណុលពីខាងក្រៅក្នុងកម្រិតទាប។[8]

10. ការចំណាយរបស់ជាតិសម្រាប់ឆ្នាំ២០២៥ ត្រូវបានប៉ាន់ស្មានថាមានចំនួន ៣៨,៩៥ ទ្រីលានរៀល (៩,៧ ពាន់លានដុល្លារ) ដែលឆ្លុះបញ្ចាំងការកើនឡើង ២,៣៤ ភាគរយ បើធៀបនឹងឆ្នាំ២០២៤ ។ ការបែងចែកថវិកាសម្រាប់វិស័យសុខាភិបាល និងអប់រំ ត្រូវបានប៉ាន់ស្មានថាកើនឡើង ០,១ និង ៨,៤៤ ភាគរយ ដោយឡែកពីគ្នា។ ទោះបីជាយ៉ាងនេះក្តី បើគិតជាសមាមាត្រនៃ GDP ការប៉ាន់ប្រមាណចំណាយសម្រាប់វិស័យអប់រំ

---

[2] "ការគាបសង្កត់ឆ្លងដែន" តំណាងឱ្យសកម្មភាពដែលធ្វើឡើង ឬដឹកនាំដោយរដ្ឋ ឬតំណាងរបស់ខ្លួន ដើម្បីរារាំង លុបបំបាត់ ឬដាក់ទណ្ឌកម្មលើការប្រឆាំង ការរិះគន់ ឬការតស៊ូមតិផ្នែកសិទ្ធិមនុស្សចំពោះសកម្មភាពបែបនេះ ដែលបញ្ចេញមតិពីក្រៅប្រទេស របស់ខ្លួន។

[3] សូមមើល https://www.ohchr.org/en/statements-and-speeches/2024/06/we-must-urgently-find-our-wayback-peace-says-high-commissioner និង https://www.ohchr.org/en/statements-andspeeches/2025/03/turbulence-and-unpredictability-amid-growing-conflict-and-divided ។

[4] ធនាគារពិភពលោក "ពីការងើបឡើងវិញឆ្ពោះទៅភាពធន់៖ ការទាញប្រយោជន៍ពីទេសចរណ៍ និងពាណិជ្ជកម្មជាកត្តាជំរុញកំណើន" បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែធ្នូ ឆ្នាំ២០២៤។

[5] មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) "កម្ពុជា" របាយការណ៍ប្រចាំប្រទេសលេខ ២៥/២២ មាននៅ www.imf.org/-/media/Files/Publications/CR/2025/English/1khmea2025001-print-pdf.ashx ។

[6] ការគណនារបស់ការិយាល័យ OHCHR ផ្អែកលើធនាគារជាតិនៃកម្ពុជា ទិន្នន័យស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ និងអត្រាអតិផរណា អាចស្វែងរកបាននៅ ៖ www.nbc.gov.kh/english/economic_research/monetary_and_financial_statistics_data.php ។

[7] ការគណនារបស់ការិយាល័យ OHCHR ដោយផ្អែកលើច្បាប់ថវិកាឆ្នាំ២០២៣ និងឆ្នាំ២០២៤ (សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និងការគ្រប់គ្រង)។ ទិន្នន័យអាចស្វែងរកបាននៅ https://mef.gov.kh/documents-category/budget/page/2/ ។

[8] សូមមើល https://www.imf.org/external/Pubs/ft/dsa/DSAlist.pdf ។

នៅតែមានកម្រិតត្រឹម ២,១ ភាគរយ ហើយធ្លាក់ចុះតិចតួចក្នុងវិស័យសុខាភិបាលពី ១,៤ ភាគរយ ក្នុងឆ្នាំ ២០២៤ មកនៅត្រឹម ១,៣ ភាគរយ នៅក្នុងឆ្នាំ២០២៥។[9]

11. ការិយាល័យ OHCHR បានបន្តគាំទ្រដល់រដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលនានា ដើម្បីធ្វើឱ្យប្រសើរឡើងនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងដើម្បីលើកកម្ពស់សេដ្ឋកិច្ចសិទ្ធិមនុស្ស។ នៅខែសីហា ឆ្នាំ ២០២៤ ការិយាល័យ OHCHR បានសហការជាមួយក្រុមការងារថវិកា ដែលមានសមាជិកមកពីសង្គមស៊ីវិល ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្រ្តផ្អែកលើសិទ្ធិមនុស្សក្នុងការរៀបចំថវិកានៅកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមសរុបចំនួន ៣២ នាក់ (ស្រ្តី ១២ នាក់ និងបុរស ២០ នាក់) ដែលអញ្ជើញមកពីស្ថាប័នសិក្សាអប់រំ និងអង្គការសង្គមស៊ីវិល។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានសហការជាមួយអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងក្រុមការងារថវិកា ដើម្បីរៀបចំសិក្ខាសាលាមួយ ស្តីពី ការវិភាគថវិកាជាតិ សម្រាប់តំណាងសង្គមស៊ីវិល សរុបចំនួន ៣៤ នាក់ (ស្រ្តី ១១ នាក់ និងបុរស ២៣ នាក់)។ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានេះ ធ្វើឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពក្រុមគោលដៅទាំងនេះ ឱ្យមានមូលដ្ឋានគ្រឹះមួយដើម្បីអាចធ្វើការជាមួយរដ្ឋាភិបាល នាពេលអនាគត។

## ខ. សិទ្ធិទទួលបានសន្តិសុខសង្គម

12. រដ្ឋាភិបាលបានបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតប្រព័ន្ធគាំពារសង្គម ដែលកាន់តែមានបរិយាបន្ន និងគ្រប់ជ្រុងជ្រោយ។ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ រដ្ឋាភិបាលបានដាក់ឱ្យដំណើរការក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥[10] ក្នុងគោលបំណងតម្រង់ទិសការអភិវឌ្ឍ និងចីរភាព នៃប្រព័ន្ធគាំពារសង្គម ស្របតាមអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។[11]

13. ការិយាល័យ OHCHR បានបន្តធ្វើការជាមួយរដ្ឋាភិបាល ដើម្បីលើកកម្ពស់សិទ្ធិទទួលបានសន្តិសុខសង្គម។ នៅក្នុងខែឧសភា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានធ្វើបទបង្ហាញស្តីពីលទ្ធផលនៃ ការសិក្សាមួយ ដែលមានចំណងជើងថា "ការប៉ាន់ប្រមាណពីឆន្ទៈក្នុងការចូលរួមបង់ភាគទានក្នុងកម្មវិធីធានារ៉ាប់រងសុខភាព របស់កម្មករបម្រើការនៅក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងរាជធានីភ្នំពេញ" ដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការសិក្សានេះ បានរកឃើញថា កម្មករធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ ទោះបីជាងាយរងគ្រោះក៏ដោយ ភាគច្រើនមិនទាន់ទទួលបានបណ្ណកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ[12] ពីរដ្ឋាភិបាល ហេតុនេះពួកគេមិនត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់[13] និងអត្ថប្រយោជន៍នានាផ្សេងទៀត ក្នុងអំឡុងពេលកូវីដ-១៩ នោះទេ។ សម្រាប់អ្នកដែលទទួលបានអត្ថប្រយោជន៍ខាងលើនេះ ជំនួយដែលទទួលបានបង្ហាញថានៅមិនទាន់គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការមូលដ្ឋានរបស់ពួកគេឡើយ ហើយឆន្ទៈដែលគេចង់ចូលរួមបង់ភាគទានក្នុងកម្មវិធីធានារ៉ាប់រងសុខភាពគឺទាបខ្លាំង ធៀបនឹងកម្រិតបង់ភាគទានដែលតម្រូវ។ កម្មករជាច្រើន នៅតែមិនបានដឹងអំពីរបបគាំពារសង្គមដែលមានស្រាប់ ដែលនេះបង្ហាញឱ្យឃើញពីតម្រូវការកម្មវិធីលើកកម្ពស់ការយល់ដឹងដែលកំណត់គោលដៅជាក់លាក់ ។

---

[9] ការគណនារបស់ការិយាល័យ OHCHR ផ្អែកលើទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (សូមមើល https://mef.gov.kh/download-counter?post=11914 (ជាភាសាខ្មែរ))។

[10] សូមមើល https://data.opendevelopmentcambodia.net/library_record/national-social-protection-policyframework-2024-2035/resource/42cef6ad-7e4c-4530-afaf-a54fbc7fa408។

[11] E/C.12/KHM/CO/2 កថាខណ្ឌ ៣៣។

[12] A/HRC/54/72 កថាខណ្ឌ ៩ និង ១២ និង A/HRC/57/78 កថាខណ្ឌ ១៧។

[13] ត្រូវបានជំនួសដោយកម្មវិធីកញ្ចប់ថវិកាគ្រួសារ កាលពីខែមេសា ឆ្នាំ២០២៤។

14. ជាផ្នែកមួយ នៃការតាមដានការអនុវត្តអនុសាសន៍ទទួលបានពីការសិក្សានេះ ការិយាល័យ OHCHR បានសហការជាមួយមូលនិធិជាតិជំនួយសង្គម ដើម្បីផលិតវីដេអូចំនួនបី ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីកិច្ចគាំពារសង្គម។

## IV. សមភាព និងភាពគ្មានការរើសអើង

### ក. សមភាពយេនឌ័រ និងសិទ្ធិមនុស្សរបស់ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរយេនឌ័រ អ្នកអន្តរភេទ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទ (LGBTIQ+)

15. ដោយមានការសម្របសម្រួលជាមួយ ការិយាល័យភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN-Women) និងមូលនិធិអង្គការសហប្រជាជាតិដើម្បីប្រជាជន ការិយាល័យ OHCHR បានបន្តគាំទ្រដល់ក្រសួងកិច្ចការនារី ក្នុងដំណើរការធ្វើវិសោធនកម្មច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ[14] ស្របតាមអនុសាសន៍របស់គណៈកម្មាធិការស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។[15] ក្រសួងបានបន្តពិចារណាលើផែនទីបង្ហាញផ្លូវសម្រាប់កំណែទម្រង់ និងការវិភាគលើច្បាប់ដែលអង្គការសហប្រជាជាតិបានផ្តល់ជូន ក្នុងឆ្នាំ២០២៣ និងបានបញ្ជាក់ពីការត្រៀមខ្លួនធ្វើវិសោធនកម្មមាត្រាមួយចំនួន ដើម្បីធ្វើឱ្យប្រសើរឡើងនូវអនុលោមភាពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

16. ក្នុងខែកញ្ញា ឆ្នាំ២០២៤ តបតាមការអញ្ជើញរបស់ក្រសួងកិច្ចការនារី ការិយាល័យ OHCHR បានចូលរួមជាមួយក្រុមការងារបច្ចេកទេសធ្វើការលើ អំពើហិង្សាផ្អែកលើយេនឌ័រ និងបានផ្តល់ធាតុចូលលើសេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទីបួន (២០២៤-២០៣០) រួមទាំងការដាក់បញ្ចូលជនមានពិការភាព ដើម្បីធានាបាននូវវិធីសាស្ត្រមួយដែលមានលក្ខណៈជាអន្តរប្រសព្វ។

17. ក្នុងខែមីនា ឆ្នាំ២០២៥ ការិយាល័យ OHCHR បានប្រារព្ធទិវានារីអន្តរជាតិ ដោយបានធ្វើយុទ្ធនាការរយៈពេលមួយសប្តាហ៍ ដើម្បីបន្ទរសំឡេងថ្នាក់ដឹកនាំស្ត្រីក្នុងភាពចម្រុះរបស់ពួកគេ រួមទាំងស្ត្រីដែលជាមនុស្សថ្លង់ និងអ្នកការពារសិទ្ធិមនុស្សផងដែរ។ ការិយាល័យ OHCHR បានសហការជាមួយក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ ដើម្បីផ្សព្វផ្សាយវីដេអូចម្រៀងមួយ ច្រៀងដោយតារាចម្រៀងរ៉េបជាស្ត្រីមួយរូប ដែលចម្រៀងនេះ ព្យាយាមផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់ និងការតស៊ូមតិដើម្បីសិទ្ធិ សមភាព និងភាពអង់អាចរបស់ស្ត្រី។

18. ក្នុងអំឡុង ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ របស់កម្ពុជា ក្នុងជុំទី៤ លទ្ធផលនៃការពិនិត្យនេះ ដែលត្រូវបានអនុម័តក្នុង សម័យប្រជុំលើកទី៥៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស រដ្ឋាភិបាលកម្ពុជាបានទទួលយកអនុសាសន៍ទាំង ១២ ទាក់ទងនឹងសិទ្ធិរបស់ LGBTIQ+ រួមទាំង អនុសាសន៍ ចំនួន ៧ ដើម្បីធ្វើឱ្យស្របច្បាប់នូវសមភាពអាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា។[16] ការទទួលយកនេះ បានបង្ហាញពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់របស់រដ្ឋាភិបាលក្នុងការជំរុញសិទ្ធិរបស់ LGBTIQ+ ដែលរងការរើសអើង និងការផាត់ចេញពីសង្គម ដោយសារតែកង្វះកិច្ចគាំពារផ្នែកច្បាប់ជាក់លាក់។ ការិយាល័យ OHCHR បានបន្តសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីពិចារណាស្វែងរកផ្លូវឆ្ពោះទៅរកសមភាពអាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា នៅកម្ពុជា។

---

[14] សូមមើល https://asset.cambodia.gov.kh/mowa/2016/12/DV-Law.pdf (ជាភាសាខ្មែរ)។

[15] CEDAW/C/KHM/CO/6 កថាខណ្ឌ ២៥ (ខ) ។

[16] សូមមើលសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ ៥៧/១១៤។

19. នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤ និងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៥ ការិយាល័យ OHCHR និងក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេស បានគាំទ្រការរៀបចំព្រឹត្តិការណ៍ Pride Fest Cambodia ចំនួនពីរលើក ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែង លើកកម្ពស់សិទ្ធិស្មើគ្នា សម្រាប់ LGBTIQ+។ ក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេស បានចូលរួមជាមួយសាធារណជននៅក្នុងព្រឹត្តិការណ៍ទាំងនេះ ក្នុងការលើកកម្ពស់ការយល់ដឹង អំពីសិទ្ធិរបស់ LGBTIQ+ ដូចមានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ព្រឹត្តិការណ៍នេះបានទាក់ទាញមនុស្សជាង ៥.០០០ នាក់ ជារៀងរាល់ឆ្នាំ។

## ខ. សិទ្ធិជនជាតិដើមភាគតិច និងជនជាតិភាគតិច

20. ការិយាល័យ OHCHR បានបន្តលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងធ្វើការជាមួយតំណាងរបស់ពួកគេ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ពួកគេ។ ការិយាល័យ បានផ្តោតលើការកសាងសមត្ថភាពរបស់ជនជាតិដើមភាគតិច ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិរបស់ជនជាតិដើមភាគតិច ព្រមទាំងផ្តល់ការគាំទ្រជនជាតិដើមភាគតិចឱ្យចូលរួមជាមួយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

21. ក្នុងខែកក្កដា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានរៀបចំកម្មវិធីបណ្តុះបណ្តាលមួយស្តីពីយន្តការសិទ្ធិមនុស្សអន្តរជាតិសម្រាប់ជនជាតិដើមភាគតិច ដោយបានពង្រឹងភាពអង់អាច ដល់សិក្ខាកាម ចំនួន ២១ នាក់ (ស្ត្រី ៨ នាក់ និងបុរស ១៣ នាក់) មកពីសហគមន៍ជនជាតិដើមភាគតិចនានា ដើម្បីចូលរួមជាមួយយន្តការដែលបានបង្កើតឡើងដើម្បីការពារ និងលើកកម្ពស់សិទ្ធិរបស់ជនជាតិដើមភាគតិច។ ក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានបណ្តុះបណ្តាលតំណាងជនជាតិដើមភាគតិច ចំនួន ២២ នាក់ (ស្ត្រី ១២ នាក់ និងបុរស ១០ នាក់) ស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សម្រាប់ជនជាតិដើមភាគតិច។ កម្មវិធីទីបី ក្នុងខែឧសភា ឆ្នាំ២០២៥ រួមមានវត្តមានរបស់សមាជិកនៃយន្តការអ្នកជំនាញស្តីពីសិទ្ធិជនជាតិដើមភាគតិច បានបណ្តុះបណ្តាលតំណាងជនជាតិដើមភាគតិច ចំនួន ២០ នាក់ (ស្ត្រី ១៣ នាក់ និងបុរស ៧ នាក់) ស្តីពី ការផ្សារភ្ជាប់បញ្ហាក្នុងស្រុកជាមួយនឹងក្របខណ្ឌសិទ្ធិមនុស្សអន្តរជាតិ។

22. ក្នុងខែសីហា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានគាំទ្រដល់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក។ ការិយាល័យ OHCHR ក៏បានធ្វើយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយសង្គមរយៈពេលមួយសប្តាហ៍ផងដែរ ដើម្បីពង្រីកសំឡេងរបស់ជនជាតិដើមភាគតិចចម្រុះ។

23. នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មបានចូលជាធរមាន ដែលជាជំហានមួយដ៏សំខាន់មួយឆ្ពោះទៅរកការធានាបាននូវអត្តសញ្ញាណស្របច្បាប់សម្រាប់បុគ្គលគ្រប់រូប នៅក្នុងប្រទេសកម្ពុជា។ យ៉ាងណាក៏ដោយ គ្រួសារជនជាតិភាគតិចវៀតណាម និងគ្រួសារជាច្រើនដែលពុំមានឯកសារច្បាស់លាស់ នៅតែបន្តជួបប្រទះឧបសគ្គផ្នែករដ្ឋបាលក្នុងការទទួលបានសំបុត្រកំណើត រួមទាំងដោយសារនីតិវិធីរដ្ឋបាលពុំសូវមានបរិយាបន្ន និងកង្វះការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍ និងនីតិវិធីនៃការចុះបញ្ជីកំណើត ដែលធ្វើឱ្យពួកគេងាយរងគ្រោះក្លាយជានិបេតិកជន (ជនគ្មានសញ្ជាតិ) និងរារាំងដល់លទ្ធភាពទទួលបានសេវាសំខាន់ៗ ដូចជា ការអប់រំ ការថែទាំសុខភាព ការងារក្នុងវិស័យក្នុងប្រព័ន្ធ និងប្រព័ន្ធគាំទ្រសង្គមផ្សេងៗ។

## គ. សិទ្ធិជនមានពិការភាព

24. ជាផ្នែកមួយនៃកម្មវិធីរួមរបស់អង្គការសហប្រជាជាតិ ស្តីពីការពន្លឿនការលើកកម្ពស់សិទ្ធិជនមានពិការភាពនៅកម្ពុជា ការិយាល័យ OHCHR បានបន្តចូលរួមជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ និងអង្គការតំណាងជនមានពិការភាពនានា ដើម្បីលើកកម្ពស់វិធីសាស្រ្តផ្អែកលើសិទ្ធិមនុស្សចំពោះពិការភាព។ ការិយាល័យ OHCHR បានផ្តល់យោបល់បច្ចេកទេស ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លើសេចក្តីព្រាងច្បាប់ដែលមិនទាន់អនុម័ត ស្តីពីកិច្ចគាំពារសិទ្ធិជនមានពិការភាព និងផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨ ដែលត្រូវបានអនុម័តនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤។[17] ក្នុងខែកុម្ភៈ ឆ្នាំ ២០២៥ ការិយាល័យ OHCHR បានរៀបចំកិច្ចប្រជុំមួយជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីពិភាក្សាអំពីផែនការយុទ្ធសាស្រ្តជាមួយអង្គការសង្គមស៊ីវិល និងអង្គការតំណាងជនមានពិការភាព។

25. ការិយាល័យ OHCHR បានគាំទ្រដល់ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការពង្រឹងកិច្ចសម្របសម្រួលជាមួយក្រសួងនានារបស់រដ្ឋាភិបាល ដើម្បីបញ្ជ្រាបបរិយាបន្នពិការភាពនៅក្នុងវិស័យផ្សេងៗ។ កិច្ចប្រជុំរួមត្រូវបានរៀបចំជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងយុត្តិធម៌ ក្នុងគោលបំណងបន្តរៀបចំកម្មវិធីបណ្តុះបណ្តាល ស្តីពីសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនមានពិការភាព។ ក្នុងខែតុលា ឆ្នាំ២០២៤ កម្មវិធីនេះត្រូវបានរៀបចំនៅខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុបចំនួន ៤២ នាក់ (ស្ត្រី ១១ នាក់ និងបុរស ៣១ នាក់) រួមមានចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីមកពីសាលាដំបូង ចំនួនប្រាំបី និស្សិតច្បាប់ និងតំណាងនៃអង្គការតំណាងជនមានពិការភាព។ គ្រូឧទ្ទេសក៏រួមបញ្ចូលជនមានពិការភាពផងដែរ។

26. តបតាមសំណើរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ការិយាល័យ OHCHR បាននិងកំពុងតាក់តែងសៀវភៅណែនាំថ្នាក់ជាតិ ស្តីពីអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដើម្បីគាំទ្រដល់ការកសាងសមត្ថភាពរបស់អ្នកបង្កើតគោលនយោបាយជាតិ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានរៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ចំនួន ១៦ នាក់ (ស្ត្រី ២ នាក់ និងបុរស ១៤ នាក់) ដើម្បីធ្វើតេស្តសាកល្បងសៀវភៅណែនាំនេះ។ ការិយាល័យ OHCHR បានរៀបចំកិច្ចពិគ្រោះយោបល់ដើម្បីពិភាក្សាលើសៀវភៅណែនាំនេះ នៅខែមីនា ឆ្នាំ២០២៥ ជាមួយអ្នកចូលរួមចំនួន ៣០ នាក់ (ស្ត្រី ១១ នាក់ និងបុរស ១៩ នាក់) ក្នុងនោះរួមទាំងជនមានពិការភាពចម្រុះ ចំនួន ១០ នាក់ មកពីអង្គការសង្គមស៊ីវិល និងអង្គការតំណាងជនមានពិការភាព។

27. ការិយាល័យ OHCHR បានបន្តផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីបញ្ចប់របាយការណ៍ដំបូងរបស់រដ្ឋភាគី សម្រាប់ផ្ញើជូនគណៈកម្មាធិការស្តីពីសិទ្ធិជនពិការ ដែលកាលបរិច្ឆេទផុតកំណត់ត្រូវផ្ញើរបាយការណ៍ គឺនៅក្នុងខែមករា ឆ្នាំ២០១៥។ រដ្ឋាភិបាលបានរៀបចំកិច្ចប្រជុំជាច្រើនលើកដើម្បីបញ្ចប់ជាស្ថាពរនូវរបាយការណ៍នេះ ក្នុងគោលបំណងដាក់ជូនគណៈកម្មាធិការស្តីពីសិទ្ធិជនពិការ នៅចុងឆ្នាំ២០២៥។

28. ការិយាល័យ OHCHR បានគាំទ្រដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិជនមានពិការភាព រួមទាំងនៅក្នុងព្រឹត្តិការណ៍នានាដើម្បីប្រារព្ធសប្តាហ៍សម្រាប់មនុស្សថ្លង់ថ្នាក់ជាតិ នៅក្នុងខែកញ្ញា ឆ្នាំ២០២៤ ទិវាជនមានពិការភាពអន្តរជាតិ នៅក្នុងខែធ្នូ ឆ្នាំ២០២៤ និងទិវាជនមានពិការភាពអូទីស្សឹម (Autism) និងដោនស៊ីនដ្រូម (Down Syndrome) កម្ពុជា កាលពីខែមេសា ឆ្នាំ២០២៥។ ការិយាល័យ OHCHR ក៏បានលើកបង្ហាញអំពីស្ត្រីមានពិការភាព នៅក្នុងយុទ្ធនាការ ១៦ ថ្ងៃ នៃភាពសកម្មនិយមប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម និងទិវាជនមានពិការភាពអន្តរជាតិ ដោយគូសបញ្ជាក់ពីប្រធានបទ "បរិយាបន្នពិការភាពលើគ្រប់វិស័យ ក្នុងយុគសម័យបរិវត្តកម្មឌីជីថល"។

[17] សូមមើល https://dac.gov.kh/en/download/33/national-disability-strategic-plan-2024-2028.html ។

## V. ការចូលរួមជាសាធារណៈ និងលំហពលរដ្ឋ

29. ការិយាល័យ OHCHR បានចងក្រងបញ្ហាប្រឈមផ្សេងៗ ចំពោះការចូលរួមរបស់ពលរដ្ឋប្រកបដោយអត្ថន័យ សុវត្ថិភាព និងបរិយាបន្ន ពីសំណាក់អង្គការសង្គមស៊ីវិល អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ រួមទាំងរបាយការណ៍នៃការឃ្លាំមើលកាន់តែខ្លាំង ការគំរាមកំហែង និងការយាយី ការចាប់ខ្លួនតាមទំនើងចិត្ត និងការរំលោភលើដំណើរការនីតិវិធីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ការរឹតត្បិតសេរីភាពរបស់ពួកគេក្នុងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម។ ការិយាល័យ OHCHR បន្តទទួលបានរបាយការណ៍ថា អ្នកសារព័ត៌មាន បានជួបប្រទះបញ្ហាប្រឈមក្នុងការបំពេញការចុះឈ្មោះតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីទទួលបានប័ណ្ណសារព័ត៌មាន ពីក្រសួងព័ត៌មាន ដែលបញ្ហានេះបានរឹតត្បិតដល់សមត្ថភាពបំពេញការងាររបស់ពួកគេ ក៏ដូចជាសេរីភាពនៃការបញ្ចេញមតិរបស់ពួកគេ ផងដែរ។[18]

30. នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤ ក្រសួងព័ត៌មានបានប្រកាសពីការអនុម័តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន ដែលត្រូវបានគេរាយការណ៍ថា មានគោលបំណងលើកកម្ពស់ក្រមសីលធម៌ និងបទដ្ឋានវិជ្ជាជីវៈសារព័ត៌មាន។ អង្គការសង្គមស៊ីវិល សមាជិកនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មាន បានកត់សម្គាល់ពីកង្វះការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងគ្រប់ជ្រុងជ្រោយ និងដំណើរការអនុម័តយ៉ាងឆាប់រហ័ស ដែលមិនបានពិចារណាឱ្យបានពេញលេញនូវធាតុចូលរបស់ភាគីពាក់ព័ន្ធនានា។ ក្នុងខែកញ្ញា ឆ្នាំ២០២៤ អ្នកកាន់អាណត្តិនីតិវិធីពិសេសមួយចំនួន បានអំពាវនាវឱ្យមានការព្យួរធម្មនុញ្ញនេះ ដោយលើកឡើងពីការព្រួយបារម្ភស្រដៀងគ្នា រាប់បញ្ចូលទាំងទាក់ទងនឹងវិសាលភាពនៃការប្រើប្រាស់ធម្មនុញ្ញ ការអនុវត្ត និងការពង្រឹងការអនុវត្តរបស់ធម្មនុញ្ញ និងបានលើកឡើងទៀតថា ធម្មនុញ្ញនេះអាចនឹងរំលោភសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងកាន់តែជាក់លាក់ជាងនេះទៅទៀត គឺសេរីភាពខាងសារព័ត៌មាន។[19]

31. អ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហានានា ដូចជាអំពីការបំផ្លិចបំផ្លាញបរិស្ថាន អំពើជួញដូរមនុស្ស និងក្តីបារម្ភពីបញ្ហាសិទ្ធិមនុស្សផ្សេងទៀត បានប្រឈមហានិភ័យខ្ពស់ចំពោះការទទួលរងអំពើហិង្សា។ កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ លោក ឈឿង ឈឹង អ្នកសារព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយអនឡាញកម្ពុជាអភិវឌ្ឍន៍ ត្រូវបានគេបាញ់នៅខេត្តសៀមរាប និងបានបាត់បង់ជីវិតពីរថ្ងៃក្រោយមកនៅក្នុងមន្ទីរពេទ្យ។ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ នគរបាល បានចាប់ខ្លួនជនសង្ស័យម្នាក់ ដែលតាមព័ត៌មាន បានសារភាពចំពោះការបាញ់សម្លាប់នេះ ដោយនិយាយថា ការបាញ់ប្រហារនេះគឺពាក់ព័ន្ធនឹងការរាយការណ៍អំពីការកាប់ឈើខុសច្បាប់។ ការបាញ់ប្រហារនេះ គឺជាការសម្លាប់អ្នកសារព័ត៌មានដំបូងគេនៅក្នុងប្រទេសកម្ពុជា គិតចាប់តាំងពីឆ្នាំ២០១៤ នៅពេលដែលលោក តាំង ទ្រី ត្រូវបានគេសម្លាប់ ខណៈដែលកំពុងរាយការណ៍អំពីការកាប់ឈើខុសច្បាប់ផងដែរ។

32. កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ លោក សឿ សុជា អ្នកយកព័ត៌មានអនឡាញរបស់សារព័ត៌មាន *Asean Daily* ត្រូវបានឃុំខ្លួនពីបទ "ញុះញង់ឱ្យមានការរើសអើង" តាមបណ្តឹងព្រហ្មទណ្ឌរបស់ប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំ ពាក់ព័ន្ធនឹងវីដេអូបង្ហោះលើទំព័របណ្តាញសង្គម *Asean Daily* អំពីការកាប់បំផ្លាញព្រៃឈើនៅក្នុងខេត្តនេះ។ នៅពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ លោក សុជា ត្រូវបានដោះលែងវិញ ដោយការព្យួរទោស បន្ទាប់ពីរូបលោកត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ ដែលក្នុងនោះលោកបានជាប់ពន្ធនាគាររយៈពេល ៥ ខែ និង ១៥ ថ្ងៃ។ ការិយាល័យ OHCHR បានទទួលរបាយការណ៍ថា ដោយសារការ

---

[18] Human Rights Committee general comment No. 34 (2011) កថាខណ្ឌ ៤៤ និង ៤៥។

[19] សូមមើល https://www.ohchr.org/en/press-releases/2024/09/cambodia-un-experts-call-suspensionprofessional-journalism-charter ។

បន្តរាយការណ៍អំពីបញ្ហាបរិស្ថានរបស់លោក មន្ត្រីមូលដ្ឋានម្នាក់ បានគំរាមលោក សុជា ថានឹងឲ្យគេចាប់បញ្ជូនលោកទៅពន្ធនាគារវិញ។

33. នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៥ លោក Gerald Flynn អ្នកសារព័ត៌មានជនជាតិអង់គ្លេស ដែលបានរស់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ និងបានរាយការណ៍អំពីបញ្ហាបរិស្ថាន ឱ្យស្ថាប័នព័ត៌មាន Mongabay ត្រូវបានបដិសេធមិនឱ្យចូលប្រទេសកម្ពុជាវិញ នៅអាកាសយានដ្ឋានខេត្តសៀមរាប។ អាជ្ញាធរអន្តោប្រវេសន៍ តាមការរាយការណ៍ បានចាត់ទុកថា លោក Gerald Flynn បានកុហកនៅលើបែបបទសុំពន្យារទិដ្ឋាការរបស់គាត់ និងបានហាមគាត់មិនឱ្យចូលប្រទេសកម្ពុជាជាអចិន្ត្រៃយ៍ ដោយមិនបានផ្តល់លទ្ធភាពឱ្យគាត់ក្នុងការប្តឹងជំទាស់នោះទេ។ លោក Flynn បានបង្ហាញមុខនៅក្នុងវីដេអូឯកសារមួយ របស់សារព័ត៌មាន France24 អំពីការកាប់បំផ្លាញព្រៃឈើ និងដានកាបូន (Carbon footprint) នៅក្នុងប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ដែលត្រូវបានក្រសួងបរិស្ថានចាត់ទុកថា "មិនពិត" ។[20]

34. នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រសួងព័ត៌មានបានចេញសេចក្តីជូនដំណឹងមួយស្តីពីការប្រើប្រាស់ឈ្មោះដែនជាតិ នៅលើប្រព័ន្ធអ៊ីនធឺណិត (national Internet domain name) ".kh"[21] យោងតាមអនុក្រឹត្យលេខ ២៨៧ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ឈ្មោះដែនជាតិនៅលើអ៊ីនធឺណិត។ សេចក្តីជូនដំណឹងនេះ បានផ្ញើទៅកាន់បណ្តាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន សមាគម និងស្ថាប័នផ្សព្វផ្សាយព័ត៌មាន ដែលធ្វើការលើវិស័យព័ត៌មាន និងសោតទស្សន៍ ក៏ដូចជាសាធារណជនទូទៅ ព្រមទាំងបាន "លើកទឹកចិត្ត" ឱ្យស្ថាប័នខាងលើនេះ ប្រើប្រាស់ដែន ".kh"។ ស្ថាប័នផ្សព្វផ្សាយព័ត៌មានមួយចំនួន បានលើកឡើងពីការព្រួយបារម្ភអំពីអនុលោមភាពនៃសេចក្តីជូនដំណឹងនេះ ជាមួយនឹងសិទ្ធិឯកជនភាព និងសេរីភាពនៃការបញ្ចេញមតិ ដោយសារតែការប្រើប្រាស់ដែននេះ នឹងដាក់ឱ្យពួកគេស្ថិតនៅក្រោមបទប្បញ្ញត្តិ និងការត្រួតពិនិត្យរបស់រដ្ឋាភិបាល ដែលអាចនាំឱ្យមានការរឹតបន្តឹងលើខ្លឹមសារ ឬការត្រួតពិនិត្យលើការផ្សព្វផ្សាយ។

35. នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងលើកទី៤[22] ក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយបានរំលឹកសមាគម និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនានា ឱ្យផ្តល់ព័ត៌មានដល់អាជ្ញាធរ អំពីគណនីធនាគារ របាយការណ៍ប្រចាំឆ្នាំ ផែនការកម្មវិធីដែលឯកភាពដោយម្ចាស់ជំនួយ និងការរៀបចំហិរញ្ញវត្ថុ និងការផ្លាស់ប្តូរលក្ខន្តិកៈ ឬការគ្រប់គ្រងរបស់ពួកគេ។ សេចក្តីជូនដំណឹងនេះ បានបញ្ជាក់ឡើងវិញនូវការហាមឃាត់ចំពោះសកម្មភាពទាំងឡាយដែលផ្ទុយនឹងលក្ខន្តិកៈរបស់ពួកគេ ដើម្បីរកប្រាក់ចំណេញ ឬផលប្រយោជន៍ផ្ទាល់ខ្លួន ឬបង្គ្រោះថ្នាក់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ការិយាល័យ OHCHR មានការព្រួយបារម្ភថា ច្បាប់ និងការអនុវត្តរបស់ច្បាប់នេះ អាចនឹងប៉ះពាល់ដល់សេរីភាពខាងសមាគម។

36. តាមសេចក្តីរាយការណ៍ អង្គការសង្គមស៊ីវិលមួយចំនួន ត្រូវបានតម្រូវឱ្យសុំការអនុញ្ញាតជាមុនពីអាជ្ញាធរ មុនពេលធ្វើសកម្មភាព ដែលបន្ទាប់មកសកម្មភាពទាំងនោះត្រូវបានតាមដានឃ្លាំមើលយ៉ាងដិតដល់ពីអាជ្ញាធរ ដោយការថតរូប និងប្រមូលព័ត៌មាន។ សកម្មភាពបែបនេះ អាចនឹងរំលោភលើសេចក្តីជូនដំណឹងលេខ ២០០៦ (២០១៨) របស់ក្រសួងមហាផ្ទៃ ដែលជូនដំណឹងដល់អភិបាលខេត្តថា អង្គការដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ អាចអនុវត្តសកម្មភាពរបស់ខ្លួនដោយគ្មានការរំខាន។[23]

[20] សូមមើល www.facebook.com/share/p/1CH7ERQRs8/ (ជាភាសាខ្មែរ)។

[21] សូមមើល https://opendevelopmentcambodia.net/announcements/notification-on-the-use-of-the-nationaldomainname-kh/ ។

[22] សូមមើល https://www.interior.gov.kh/news/bLecRqwGTrXN (ជាភាសាខ្មែរ)។

[23] សូមមើល www.facebook.com/share/p/1CiTyoDDcG/ (ជាភាសាខ្មែរ)។

37. ក្នុងខែកក្កដា ឆ្នាំ២០២៤ មានសេចក្ដីរាយការណ៍ថា អាជ្ញាធរបានចុះទៅការិយាល័យអង្គការក្រៅរដ្ឋាភិបាលចំនួនពីរ ហើយបានសាកសួរអំពីផែនការចូលរួមពិធីជួបជុំរំលឹកវិញ្ញាណក្ខន្ធលោក កែម ឡី ដែលជាអ្នកវិភាគនយោបាយឯករាជ្យ ដែលត្រូវបានគេបាញ់សម្លាប់កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦។ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ អាជ្ញាធរមូលដ្ឋាន បានបញ្ជាឱ្យសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) ដកបដាមួយចេញពីមុខការិយាល័យរបស់ខ្លួននៅក្នុងខេត្តកំពង់ចាម។ បដានេះ បានអំពាវនាវឱ្យមានការដោះលែងលោក កើត សារ៉ាយ ប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ ដែលត្រូវបានគេចាប់ខ្លួនដោយចោទប្រកាន់ពីបទ "ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម" និង "ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬបង្កឱ្យមានភាពវឹកវរ ដល់សន្តិសុខសង្គម" កាលពីខែមេសា ឆ្នាំ២០២៤ ដោយសារតែការរាយការណ៍អំពីជម្លោះនៅស្រុកគូលែន។[24]

38. ភ្លាមៗបន្ទាប់ពីការចេញផ្សាយរបាយការណ៍របស់ខ្លួនដែលមានចំណងជើងថា "ឧបសគ្គរារាំងភាពជាតំណាង៖ សេរីភាពសហជីពក្នុងប្រទេសកម្ពុជា" កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤[25] មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) បានប្រឈមមុខនឹងសកម្មភាពមួយចំនួន ដែលត្រូវបានគេធ្វើឡើងរួមគ្នាហាក់ដូចជាការយាយី ឬការបំភិតបំភ័យ។ របាយការណ៍ខាងលើនេះ បានវាយតម្លៃកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា ដែលជាគំនិតផ្តួចផ្តើមរួមគ្នារបស់អង្គការពលកម្មអន្តរជាតិ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោក បានកំណត់សញ្ញាណពីការខកខានមិនបានត្រួតពិនិត្យតាមដានឱ្យបានគ្រប់គ្រាន់ចំពោះការរំលោភលើសេរីភាពក្នុងការបង្កើតសហជីពនៅក្នុងរោងចក្រកាត់ដេរ និងបានផ្តល់ជាអនុសាសន៍ដើម្បីកែលម្អតម្លាភាព និងយន្តការបណ្តឹងសារទុក្ខ។ នៅថ្ងៃទី២៤ ខែមិថុនា ក្រសួងមហាផ្ទៃបានប្រកាសពីការស៊ើបអង្កេតទៅលើអង្គការសង់ត្រាល់ ទាក់ទងនឹងប្រតិបត្តិការ និងការប្រើប្រាស់មូលនិធិបរទេសរបស់អង្គការនេះ ។ កាលពីថ្ងៃទី២៧ ខែមិថុនា ប្រធានសហភាពសហជីពរក្សាសិទ្ធិកម្មករកម្ពុជា បានដាក់ពាក្យទៅតុលាការប្តឹងលោក ឃុន ថារ៉ូ អ្នកគ្រប់គ្រងកម្មវិធីអង្គការសង់ត្រាល់ ពី បទបរិហារកេរ្តិ៍ បទបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះ និង "បទញុះញង់ឱ្យមានការរើសអើង" ចំពោះសហជីព ពាក់ព័ន្ធនឹងបទសម្ភាសន៍របស់លោកជាមួយវិទ្យុអាស៊ីសេរីកាលពីថ្ងៃទី១៥ ខែមិថុនា។ នៅថ្ងៃទី២៨ ខែមិថុនា និងថ្ងៃទី២ ខែកក្កដា សហភាពពលកម្មជាតិកម្ពុជា និងសម្ព័ន្ធសហជីពជាតិ បានដាក់ពាក្យបណ្តឹងជាផ្លូវការទៅកាន់ក្រសួងមហាផ្ទៃ ប្រឆាំងនឹងអង្គការសង់ត្រាល់។ នៅថ្ងៃទី៨ ខែកក្កដា អង្គការសង់ត្រាល់ បានទទួលលិខិតមួយច្បាប់ពីអាជ្ញាធរសវនកម្មជាតិ ដែលជូនដំណឹងដល់អង្គការសង់ត្រាល់អំពីការធ្វើសវនកម្ម គ្របដណ្តប់លើរយៈពេលចាប់ពីឆ្នាំ ២០២១-២០២៤ ។ ទោះបីជាមានការធ្វើសវនកម្មរួចហើយក៏ដោយ ក៏របាយការណ៍សវនកម្មនេះ មិនទាន់ត្រូវបានចេញផ្សាយនៅឡើយទេ។

39. ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានចងក្រងបាតុកម្មយ៉ាងហោចណាស់ចំនួន ៦៤ ដែលភាគច្រើនទាក់ទងនឹងការតវ៉ាកំពុងបន្តដោយ សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៅក្រុមហ៊ុនណាហ្គាវើលដ៍ ដើម្បីស្វែងរកដំណោះស្រាយចំពោះការទាមទាររបស់ពួកគេ ពីសាជីវកម្មកាស៊ីណូណាហ្គាវើលដ៍។ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥ សមាជិកនៃសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរប្រមាណ ៣០នាក់ បានប្រមូលផ្តុំគ្នានៅក្រសួងការងារដើម្បីតាមដានពាក្យបណ្តឹងដែលបានដាក់តាំងពីឆ្នាំ២០២២ ដើម្បីស្វែងរកការអន្តរាគមន៍ពីអាជ្ញាធរ។ ជាមួយគ្នានេះ កញ្ញា ឈឹម ស៊ីថរ ប្រធានសហភាពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ ត្រូវបានដោះលែងពីពន្ធនាគារ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤ ក្រោយបំពេញទោសរយៈពេល២ឆ្នាំ ពីបទ "ញុះញង់បង្កភាពវឹកវរដល់សន្តិសុខសង្គម" ទាក់ទងនឹងការអនុវត្តសិទ្ធិរបស់គាត់ក្នុងការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម។[26]

[24] A/HRC/57/78 កថាខណ្ឌ ៤១។

[25] សូមមើល https://central-cambodia.org/archives/6989 ។

[26] A/HRC/51/63 កថាខណ្ឌ ១៧ និង ១៨; A/HRC/54/72 កថាខណ្ឌ ៣៩; និង A/HRC/57/78 កថាខណ្ឌ ៤២។

40. ការិយាល័យ OHCHR បានសង្កេតឃើញការធ្លាក់ចុះលំហពលរដ្ឋ ដែលត្រូវបានកំណត់លក្ខណៈដោយការឃុំខ្លួនតាមទំនើងចិត្ត និងការចោទប្រកាន់តាមផ្លូវតុលាការ ដែលផ្តោតគោលដៅទៅលើអ្នកប្រឆាំងនយោបាយ អ្នកការពារសិទ្ធិមនុស្ស សកម្មជន និងអ្នកសារព័ត៌មាន ដែលប្រើប្រាស់សិទ្ធិសេរីភាពរបស់ពួកគេក្នុងការបញ្ចេញមតិ បង្កើតសមាគម ឬការជួបប្រជុំដោយសន្តិវិធី។ នៅក្នុងខែសីហា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានទទួលរបាយការណ៍ថា យ៉ាងហោចណាស់មានបុគ្គលចំនួន ៦៨ នាក់ (ស្ត្រី ១៦ នាក់ និងបុរស ៥២ នាក់) ត្រូវបានចាប់ខ្លួន ពាក់ព័ន្ធនឹងការតវ៉ាដែលត្រូវបានប្រកាសនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ប្រឆាំងនឹងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ-វៀតណាម។ ផ្អែកលើព័ត៌មានដែលការិយាល័យ OHCHR បានប្រមូល បានឱ្យដឹងថា បុគ្គលចំនួន ២៧ នាក់ ដែលត្រូវបានចាប់ខ្លួនរងការចោទប្រកាន់ពីបទ "រួមគំនិតក្បត់" ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ៥ ដល់ ១០ឆ្នាំ។ ខណៈបុគ្គលមួយចំនួន កំពុងស្ថិតក្នុងការឃុំខ្លួននៅឡើយ បុគ្គលជាច្រើនទៀត ត្រូវបានគេរាយការណ៍ថា ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ បន្ទាប់ពីបានធ្វើការសុំទោសជាសាធារណៈចំពោះថ្នាក់ដឹកនាំប្រទេស។ ករណីទាំងនេះ ត្រូវបានលើកឡើងដោយអ្នកកាន់អាណត្តិនីតិវិធីពិសេសមួយចំនួន នៅក្នុងលិខិតមួយ កាលពីខែ ឧសភា ឆ្នាំ ២០២៥។[27]

41. កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤ សកម្មជនបរិស្ថានចំនួន ៦នាក់ ដែលធ្វើការឃ្លាំមើលការកាប់ឈើខុសច្បាប់ និងកាប់បំផ្លាញព្រៃឈើ នៅភូមិស្រែសាម ឃុំតាឡាត ស្រុកសេសាន ត្រូវបានសមត្ថកិច្ចខេត្តស្ទឹងត្រែងចាប់ខ្លួន។ ពួកគេត្រូវបានដោះលែងពីរថ្ងៃក្រោយមក តាមសេចក្តីរាយការណ៍ថា បន្ទាប់ពីត្រូវបានបង្ខំឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ មិនឱ្យចែករំលែកព័ត៌មានដែលពួកគេបានប្រមូលជាសាធារណៈ ក្រោមការគំរាមកំហែងពីការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌពីបទចារកម្ម។

42. ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ការិយាល័យ OHCHR បានទទួលរបាយការណ៍ថា អ្នកប្រឆាំងនយោបាយយ៉ាងហោចណាស់ ២៦ នាក់ (ស្ត្រី ៥ នាក់ និងបុរស ២១ នាក់) ត្រូវបានចាប់ខ្លួន ឬកោះហៅមកសាកសួរជុំវិញការចោទប្រកាន់ពីបទព្រហ្មទណ្ឌ រួមមាន "ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬបង្កភាពវឹកវរដល់សន្តិសុខសង្គម" "ញុះញង់ឱ្យមានការរើសអើង" ប្រមាថចំពោះអង្គព្រះមហាក្សត្រ និងរួមគំនិតក្បត់។[28] ពួកគេ ៥ នាក់ (បុរសទាំងអស់) ត្រូវបានដោះលែងឱ្យនៅក្រៅឃុំជាមួយនឹងបទចោទប្រកាន់ដែលកំពុងរង់ចាំកាត់ក្តី តាមសេចក្តីរាយការណ៍ បន្ទាប់ពីពួកគេបានសុំទោសជាសាធារណៈ និងចូលរួមជាមួយគណបក្សកាន់អំណាច។ ការិយាល័យ OHCHR បានកត់ត្រាថា ចាប់តាំងពីឆ្នាំ២០២០ មក អ្នកទោសនយោបាយយ៉ាងហោចណាស់ចំនួន ៣៤ នាក់ (ស្ត្រី ៦ នាក់ និងបុរស ២៨ នាក់) នៅតែស្ថិតក្នុងការឃុំខ្លួន ដែលភាគច្រើនត្រូវបានចោទប្រកាន់ពីបទក្បត់ជាតិ រួមគំនិតក្បត់ ញុះញង់ និងប្រមាថចំពោះអង្គព្រះមហាក្សត្រ។

43. កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ លោក រ៉ុង ឈុន ទីប្រឹក្សាគណបក្សប្រឆាំងមកពីគណបក្សកម្លាំងជាតិ និងជាអ្នកដឹកនាំសហជីព ត្រូវបានចោទប្រកាន់ពីបទ "ញុះញង់បង្កភាពវឹកវរដល់សន្តិសុខសង្គម" និងជាជនល្មើសមិនរាងចាល ក្រោមមាត្រា ៤៩៤ មាត្រា ៤៩៥ និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ។ បទចោទប្រកាន់ទាំងនេះ គឺទាក់ទងនឹងសន្ទរកថារបស់លោក អំឡុងពិធីបើកសម្ពោធការិយាល័យគណបក្សក្នុងខេត្តកណ្តាល កាលពីខែកក្កដា ឆ្នាំ២០២៤ ដែលពេលនោះ លោកបានរិះគន់រដ្ឋាភិបាលចំពោះការខកខានមិនបានស្តារលទ្ធិប្រជាធិបតេយ្យឡើងវិញ ក៏ដូចជាបទសម្ភាសន៍របស់លោក ជាមួយវិទ្យុអាស៊ីសេរី កាលពីខែសីហា ឆ្នាំ២០២៤ ដែលលោកបានរិះគន់តំបន់ត្រីកោណអភិវឌ្ឍន៍។ កាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៥ លោក រ៉ុង ឈុន ត្រូវបានតុលាការសាលាដំបូងរាជធានីភ្នំពេញសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៤ឆ្នាំ និង

---

[27] សូមមើល KHM 2/2025 ។ លិខិតទំនាក់ទំនងទាំងអស់ដែលបានរៀបរាប់នៅក្នុងរបាយការណ៍បច្ចុប្បន្ននេះអាចស្វែងរកបានពី https://spcommreports.ohchr.org/Tmsearch/TMDocuments

[28] ក្រមព្រហ្មទណ្ឌ មាត្រា ៤៩៥, ៤៩៦, ៤៥៣, និង ៤៣៧ (ស្ទួន)។

ពិន័យជាប្រាក់ចំនួន ៤ លានរៀល ព្រមទាំងដកសិទ្ធិបោះឆ្នោត និងឈរឈ្មោះបោះឆ្នោតជាអចិន្ត្រៃយ៍។ លោក វ៉ុង ឈុន នាពេលកន្លងមកធ្លាប់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ពីខែកក្កដា ឆ្នាំ២០២០ ដល់ខែវិច្ឆិកា ឆ្នាំ២០២១ ពីបទ "ញុះញង់ឱ្យបង្កភាពវឹកវរដល់សន្តិសុខសង្គម" ជុំវិញការបញ្ចេញទស្សនៈទាក់ទងនឹងការបាត់បង់ទឹកដី ក្នុងការបោះបង្គោលព្រំដែនកម្ពុជា និងវៀតណាម។[29]

44. នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ ការិយាល័យ OHCHR និងអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ (UNESCO) បានរៀបចំសន្និសីទមួយ ស្តីពីទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន ដែលមានអ្នកចូលរួមចំនួន ១៨០ នាក់។ សន្និសីទនេះ បានសម្របសម្រួលកិច្ចសន្ទនារវាងអ្នកសារព័ត៌មាន និងអាជ្ញាធរជាតិ ដោយពិនិត្យមើលក្របខណ្ឌគតិយុត្តជាតិ និងអន្តរជាតិ ស្តីពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការអនុវត្តរបស់តុលាការនៅកម្ពុជា ការអនុវត្តល្អៗក្នុងតំបន់ និងគំនិតផ្តួចផ្តើមសុវត្ថិភាពក្នុងប្រទេស។ មានការលើកឡើងពីក្តីព្រួយបារម្ភជាមួយអាជ្ញាធរ ពាក់ព័ន្ធនឹងការប្រើប្រាស់ច្បាប់មិនត្រឹមត្រូវ ដើម្បីរឹតត្បិតសេរីភាពសារព័ត៌មាន ក៏ដូចជាពាក់ព័ន្ធនឹងរបៀបបំភិតបំភ័យផ្សេងៗទៀតមកលើអ្នកសារព័ត៌មាន និងអ្នកបម្រើការងារខាងសារព័ត៌មាន។

45. ការិយាល័យ OHCHR មានការព្រួយបារម្ភចំពោះរបាយការណ៍ដែលអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងអ្នកនយោបាយ ដែលរងការចោទប្រកាន់ ជាប់ចោទពីបទព្រហ្មទណ្ឌ ឃាត់ខ្លួន ឬកាត់ទោសបន្ទាប់ពីអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពខាងសមាគម បានទទួលរងសម្ពាធឱ្យធ្វើការសុំទោសជាសាធារណៈចំពោះរដ្ឋាភិបាល។ ការសុំទោសបែបនេះ ដែលជួនកាលអមជាមួយនឹងសំណើសុំចូលរួមជាមួយគណបក្សកាន់អំណាច ហាក់ដូចជាបង្កើតទម្រង់មួយនៃការដាក់សម្ពាធហួសហេតុ ដែលអាចនឹងឈានទៅការរំលោភសិទ្ធិមនុស្សជាច្រើន រួមទាំងសិទ្ធិទទួលបានសេរីភាព និងសន្តិសុខ និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ បុគ្គលដែលត្រូវបានដោះលែងបន្ទាប់ពីការសុំទោស បានរាយការណ៍ពីអារម្មណ៍អសន្តិសុខផ្លូវច្បាប់ ដោយភ័យខ្លាចថាដំណើរការនីតិវិធីអាចត្រូវបានសើរើឡើងវិញ ឬដាក់ទោសឱ្យជាប់ពន្ធនាគារឡើងវិញ ប្រសិនបើពួកគេបញ្ចេញមតិរិះគន់ ឬជំទាស់ម្តងទៀត។

46. ចាប់តាំងពីដើមឆ្នាំ២០២៤ មក ការិយាល័យ OHCHR បានចងក្រងករណីសុំទោសដោយបង្ខំចំនួន ៣៤ករណី ដែលក្នុងនោះ ៤ ករណីបានកើតឡើងក្នុងឆ្នាំ២០២៥។ ការសុំទោសជាញឹកញាប់ត្រូវបានធ្វើឡើងដោយសំណេរផ្ទាល់ដៃ និងត្រូវបានផ្សព្វផ្សាយ ឬចែកចាយ តាមរយៈសេចក្តីថ្លែងការណ៍ជាវីដេអូដែលបានថតទុកជាមុន ខណៈពេលដែលបុគ្គលទាំងនោះកំពុងត្រូវបានឃុំខ្លួន ហើយជួនកាលក៏កំពុងស្ថិតក្នុងឯកសណ្ឋានពន្ធនាគាររបស់ពួកគេ។ ក្នុងករណីភាគច្រើន ការសុំទោសត្រូវបានចេញផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមដោយបុគ្គលដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល។

47. មួយក្នុងចំណោមករណីទាំងនោះ ដែលកាលពីខែតុលា ឆ្នាំ២០២៤ អ្នកកាសែតម្នាក់ គឺលោក ម៉ិច ដារា ត្រូវបានចាប់ឃុំខ្លួន និងចោទប្រកាន់ពីបទ "ញុះញង់បង្កភាពវឹកវរដល់សន្តិសុខសង្គម" ជុំវិញការបង្ហោះមតិតាមបណ្តាញសង្គមដោយចោទថា មានការបំផ្លិចបំផ្លាញបរិស្ថាននៅព្រះវិហារពុទ្ធសាសនាមួយកន្លែង។ បីសប្តាហ៍ក្រោយមក គាត់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន និងដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការបន្ទាប់ពីគាត់បានចេញលិខិតសុំទោសជាសាធារណៈទៅកាន់រដ្ឋាភិបាល។ ប៉ុន្មានថ្ងៃក្រោយមក លោកបានប្រកាសថាលោកឈប់ធ្វើការងារជាអ្នកសារព័ត៌មាន។ គិតត្រឹមពេលចេញផ្សាយរបាយការណ៍បច្ចុប្បន្ននេះ ការចោទប្រកាន់លើរូបគាត់មិនទាន់ត្រូវបានទម្លាក់ចោលនៅឡើយទេ ហើយក៏មិនមានការបង្ហាញថាតើពេលណាករណីរបស់គាត់អាចនឹងត្រូវគេយកមកជំនុំជម្រះក្តីនោះដែរ។

[29] A/HRC/48/49 កថាខណ្ឌ ១៣។

48. ដោយសារការកើនឡើងនូវបញ្ហាប្រឈមចំពោះសេរីភាពខាងការបញ្ចេញមតិ និងការភ័យខ្លាចចំពោះការចាប់ខ្លួន អ្នកការពារសិទ្ធិមនុស្ស និងតួអង្គនយោបាយមួយចំនួន បានស្វែងរកការជ្រកកោននៅក្នុងប្រទេសជិតខាង។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ការិយាល័យ OHCHR បានចងក្រងសំណុំរឿងអ្នកនយោបាយ និងសកម្មជនសិទ្ធិមនុស្សចំនួនប្រាំមួយនាក់ រួមទាំងសមាជិកក្រុមគ្រួសាររបស់ពួកគេសរុបចំនួន ១៨នាក់ (ស្ត្រី ៨នាក់ និងបុរស ១០នាក់) បានភៀសខ្លួនពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ ក្នុងកាលៈទេសៈដូចដែលបានរៀបរាប់ខាងលើ។ បុគ្គលទាំង ១៨នាក់ត្រូវបានទទួលស្គាល់ជាជនភៀសខ្លួនដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ហើយកំពុងរង់ចាំការតាំងទីលំនៅថ្មីទៅកាន់ប្រទេសទីបី ខណៈរបាយការណ៍នេះកំពុងត្រូវបានរៀបចំ។

49. ទន្ទឹមនឹងនេះ ការិយាល័យ OHCHR បានបន្តចងក្រងឯកសារអំពីការកើនឡើងនៃការគាបសង្កត់ករណីឆ្លងដែន។ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤ សកម្មជននយោបាយកម្ពុជា ៥នាក់ (ស្ត្រី ៣នាក់ និងបុរស ២នាក់) និងសមាជិកគ្រួសាររបស់ពួកគេ២នាក់ រួមទាំងកុមារអាយុ៥ឆ្នាំម្នាក់ ដែលបានភៀសខ្លួនទៅប្រទេសថៃកាលពីឆ្នាំ២០២២ ត្រូវបានបញ្ជូនមកកម្ពុជាវិញដោយបង្ខំ។ សកម្មជនទាំងនេះ រួមមានសមាជិកគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ និងគណបក្សភ្លើងទៀនជាគណបក្សជំទាស់។ សកម្មជនទាំងនេះត្រូវបានទទួលស្គាល់ថាជាជនភៀសខ្លួនដោយ UNHCR ហើយសមាជិកគ្រួសារម្នាក់កំពុងរង់ចាំការកំណត់ឋានៈជាជនភៀសខ្លួន។ ពេលមកដល់ប្រទេសកម្ពុជា ពួកគេត្រូវបានចោទប្រកាន់ពីបទ "រួមគំនិតក្បត់" តាមមាត្រា ៤៥៣ នៃក្រមព្រហ្មទណ្ឌ ដោយសារការបញ្ចេញមតិលើបណ្តាញសង្គមពាក់ព័ន្ធនឹងតំបន់ត្រីកោណអភិវឌ្ឍន៍ ។

50. កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៤ អ្នកស្រី នួន ធឿន ជាពលករខ្មែរបម្រើការងារតាមផ្ទះមួយរូប ត្រូវបានអាជ្ញាធរម៉ាឡេស៊ីចាប់ខ្លួននៅផ្ទះថៅកែរបស់គាត់ ក្នុងប្រទេសម៉ាឡេស៊ី ជាកន្លែងដែលគាត់ បានធ្វើការអស់រយៈពេលជាង ១៥ ឆ្នាំមកហើយ។ អ្នកស្រីត្រូវបាននិរទេសមកកម្ពុជា នៅថ្ងៃទី៣០ ខែកញ្ញា ហើយត្រូវចោទប្រកាន់ពីបទប្រមាថចំពោះអង្គព្រះមហាក្សត្រ និង "ញុះញង់ឱ្យមានការរើសអើង" ចំពោះការបញ្ចេញមតិនៅលើបណ្តាញផ្សព្វផ្សាយសង្គម។ នៅខែមីនា ឆ្នាំ២០២៥ អ្នកស្រីត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ រយៈពេល ២៤ ខែ។ អ្នកស្រីបានបញ្ជាក់មកកាន់ការិយាល័យ OHCHR ថា អ្នកស្រីមិនត្រូវបានគេបង្ហាញដីកាចាប់ខ្លួនណាមួយនៅក្នុងប្រទេសកម្ពុជា ឬម៉ាឡេស៊ីឡើយ ហើយក៏មិនទទួលបានការបញ្ជាក់ពីមូលហេតុនៃការចាប់ខ្លួនរបស់អ្នកស្រីដែរ។

51. កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២៥ លោក លឹម គឹមយ៉ា មានសញ្ជាតិ ខ្មែរ និងបារាំង និងជាអតីតអ្នកតំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ ត្រូវបានគេបាញ់សម្លាប់នៅពេលដែលរូបលោកធ្វើដំណើរដល់ទីក្រុងបាងកក ដោយចេញដំណើរពីខេត្តសៀមរាបជាមួយភរិយារបស់លោក។ នៅថ្ងៃបន្ទាប់ ជនសង្ស័យជនជាតិថៃម្នាក់ត្រូវបានចាប់ខ្លួននៅកម្ពុជា ហើយត្រូវបានប្រគល់ឱ្យអាជ្ញាធរថៃតាមសំណើរបស់ភាគីថៃ។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ជនជាតិខ្មែរពីរនាក់ផ្សេងទៀតដែលត្រូវបានសង្ស័យថាជាប់ពាក់ព័ន្ធនឹងការបាញ់សម្លាប់នេះ មិនទាន់ត្រូវបានចាប់ខ្លួននៅឡើយទេបើទោះបីជាមានការចេញនិវេទន៍ក្រហមដោយស្ថាប័នប៉ូលិសឧក្រិដ្ឋកម្មអន្តរជាតិ (INTERPOL) យ៉ាងណាក៏ដោយ។ មូលហេតុនៅពីក្រោយការសម្លាប់នេះនៅមិនទាន់ដឹងច្បាស់នៅឡើយទេ។

52. ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ការិយាល័យ OHCHR បានតាមដានការជំនុំជម្រះក្តីចំនួន ៣៤ លើកពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១៩ ករណី នៃបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ ជុំវិញការបញ្ចេញមតិមិនពេញចិត្តជាសាធារណៈ ចំពោះរដ្ឋាភិបាល ឬរិះគន់គោលនយោបាយសាធារណៈ ដែលការបញ្ចេញមតិនេះត្រូវបានការពារដោយសិទ្ធិក្នុងការបញ្ចេញមតិ។ សំណុំរឿងចំនួន ១០ ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទ "ញុះញង់ឱ្យមានភាពវឹកវរដល់សន្តិសុខសង្គម" ឬ "ញុះញង់ឱ្យមានការរើសអើង" តាមមាត្រា ៤៩៥ និង ៤៩៦ នៃក្រមព្រហ្មទណ្ឌ។ និយមន័យមិនច្បាស់លាស់ និងទូលំទូលាយនៃ "ការបង្កភាពវឹកវរដល់សន្តិសុខសង្គម"

គឺមិនស្របគ្នាជាមួយនឹងគោលការណ៍នៃនីត្យានុកូលភាព និងភាពប្រាកដប្រជាផ្នែកច្បាប់ឡើយ។ និយមន័យមិនច្បាស់លាស់នេះ បានបណ្ដាលឱ្យអាជ្ញាធរធ្វើការបកស្រាយ និងអនុវត្ត តាមរបៀបមួយដែលដាក់កម្រិតយ៉ាងខ្លាំងទៅលើសេរីភាពខាងការនិយាយស្ដី និងការចូលរួមជាសាធារណៈ។ ការរឹតបន្តឹងផ្នែកច្បាប់ទៅលើសេរីភាពជាមូលដ្ឋានត្រូវតែកំណត់និយមន័យជាដាច់ខាត និងឱ្យបានច្បាស់លាស់ រួមទាំងសកម្មភាពហាមឃាត់ជាក់លាក់ ដើម្បីទប់ស្កាត់ការអនុវត្តតាមទំនើងចិត្ត។[30] ក្នុងអំឡុងការជំនុំជម្រះក្ដីទាំងនេះ ការិយាល័យ OHCHR បានសង្កេតឃើញការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិទទួលបានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្ដី (សមភាពចំពោះនីតិវិធីជម្រះក្ដី) សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីឯករាជ្យ និងមិនលម្អៀង ព្រមទាំងសិទ្ធិផ្សេងទៀតរបស់បុគ្គល ដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ។

53. ចាប់ពីថ្ងៃទី២៩ ខែឧសភា ដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានតាមដានសវនាការចំនួនប្រាំមួយ នៅសាលាដំបូងរាជធានីភ្នំពេញ ជុំវិញការកាត់ក្ដីសកម្មជនចំនួន ១០នាក់ (ស្ត្រី ៤នាក់ និងបុរស ៦នាក់) មកពីក្រុមមាតាធម្មជាតិកម្ពុជា។ សវនាការនេះមានជនជាប់ចោទតែ៥នាក់ប៉ុណ្ណោះចូលរួម។ ចុងចោទ មិនត្រូវបានអនុញ្ញាតឱ្យសាកសួរផ្នែកខ្លះនៃភស្តុតាងដែលប្រើប្រាស់ប្រឆាំងនឹងពួកគេទេ ហើយចុងចោទម្នាក់ត្រូវបានប្រាប់ថាការមិនឆ្លើយសំណួរនឹងបង្ហាញថាមានទោស។ ភស្តុតាងដាក់បន្ទុកត្រូវបានដាក់ទៅលើជនជាប់ចោទដោយបំពានលើការសន្មតទុកជាមុនថាគ្មានទោស។ លើសពីនេះ ជនជាប់ចោទមិនបានដឹងជាមុនអំពីសកម្មភាពជាក់លាក់នានា ដែលពួកគេកំពុងត្រូវបានចោទប្រកាន់សម្រាប់រយៈពេលប្រាំបួនឆ្នាំនេះនោះទេ។ ពួកគេទាំងអស់ត្រូវបានផ្ដន្ទាទោសកាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ ឱ្យជាប់ពន្ធនាគារចាប់ពី ៦ ឆ្នាំ ដល់ ៨ ឆ្នាំពីបទ "រួមគំនិតក្បត់" តាមមាត្រា ៤៥៣ នៃក្រមព្រហ្មទណ្ឌ ហើយពួកគេបីនាក់រងការចោទប្រកាន់ពីបទប្រមាថចំពោះអង្គព្រះមហាក្សត្រ តាមមាត្រា ៤៣៧ (ស្ទួន) ។ ជាក់ស្ដែង ជនជាប់ចោទមួយចំនួន គឺនៅជាអនីតិជននៅឡើយ (អាយុ ១១, ១៣, ១៤ និង ១៦ ឆ្នាំ) នៅពេលដែលព្រឹត្តិការណ៍ទាំងនេះកើតឡើង មិនត្រូវបានយកមកពិចារណាក្នុងអំឡុងពេលសវនាការឬការកាត់ទោសនោះទេ។ អ្នកកាន់អាណត្តិនីតិវិធីពិសេសមួយចំនួនបានលើកឡើងពីការព្រួយបារម្ភអំពីការជំនុំជម្រះក្ដីនេះ នៅក្នុងលិខិតទំនាក់ទំនងដែលបានផ្ញើ កាលពីខែឧសភា ឆ្នាំ២០២៥។[31]

## VI. ការចូលរួមជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិ

### ក. កំណែទម្រង់ស្ថាប័ន និងច្បាប់

54. ការិយាល័យ OHCHR បានបន្តផ្ដល់ជំនួយបច្ចេកទេសដល់ គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ក្នុងគោលបំណងពង្រឹងតួនាទីរបស់ស្ថាប័នមួយនេះ ជាយន្តការបង្ការថ្នាក់ជាតិ។ ក្នុងខែមិថុនា និងខែកក្កដា ឆ្នាំ ២០២៤ ការិយាល័យ OHCHR បានសហការជាមួយគណៈកម្មាធិការនេះ ដើម្បីរៀបចំវគ្គបណ្ដុះបណ្ដាល នៅខេត្តចំនួន ៤ សម្រាប់មន្ត្រីអនុវត្តច្បាប់ មន្ត្រីពន្ធនាគារ មន្ត្រីតុលាការ និងមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្តចំនួន ៧៤២ នាក់ (ស្ត្រី ៩៣ នាក់ និងបុរស ៦៤៩ នាក់) ស្ដីពីបទដ្ឋានជាតិ និងអន្តរជាតិ ស្ដីពីការបង្ការទារុណកម្ម ក៏ដូចជាតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម។ ការិយាល័យ OHCHR ក៏បានផ្ដល់វគ្គបណ្ដុះបណ្ដាលដល់គណៈកម្មាធិការ ស្ដីពីច្បាប់អន្តរជាតិពាក់ព័ន្ធនឹងការបង្ការទារុណកម្ម ក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ដោយមានសិក្ខាកាមចូលរួមចំនួន ២៦ នាក់ (ស្ត្រី ៦ នាក់ និងបុរស ២០ នាក់) និងវគ្គបណ្ដុះបណ្ដាលស្ដីពីការ

[30] កតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៩ (៣)។ សូមមើលបន្ថែម គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅ លេខ ៣៤ (២០១១)។

[31] សូមមើល KHM 3/2025 ។

ត្រួតពិនិត្យកន្លែងឃុំខ្លួន ក្នុងខែឧសភា ឆ្នាំ២០២៥ ដោយមានសិក្ខាកាមចូលរួមចំនួន ២៩ នាក់ (ស្ត្រី ៧ នាក់ និងបុរស ២២ នាក់)។

55. ក្នុងខែកុម្ភៈ ឆ្នាំ២០២៥ ការិយាល័យ OHCHR បានផ្តល់ប្រអប់ដាក់បណ្តឹងចំនួន ៩០០ ដែលមានបិទខិត្តប័ណ្ណព័ត៌មាន ដល់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់អ្នកជាប់ឃុំ។ ប្រអប់ទាំងនេះដែលនឹងត្រូវយកទៅដាក់នៅតាមទីកន្លែងឃុំឃាំង និងនៅតាមប៉ុស្តិ៍នគរបាលទូទាំងប្រទេស ហើយនឹងត្រូវត្រួតពិនិត្យតាមដានដោយគណៈកម្មាធិការ គឺជាឧបករណ៍មួយដើម្បីផ្តល់ភាពអង់អាចដល់ជនជាប់ឃុំ និងក្រុមគ្រួសាររបស់ពួកគេ ឱ្យរាយការណ៍អំពីការប្រព្រឹត្តមិនគប្បីផ្សេងៗ។

56. ក្នុងខែកញ្ញា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានបើកវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ ផ្តោតលើសិទ្ធិមនុស្ស ជាលើកដំបូង ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ២៧ នាក់ (ស្ត្រី ១៣ នាក់ បុរស ១១ នាក់ និង អ្នកមានយេនឌ័រចម្រុះ ចំនួន៣ នាក់) មកពីស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងពង្រឹងសមត្ថភាពក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។

57. ការិយាល័យ OHCHR បានបន្តតស៊ូមតិ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដែលសេចក្តីព្រាងច្បាប់ស្តីពីស្ថាប័ននេះនៅពុំទាន់ត្រូវបានអនុម័ត តាំងពីពេលដែលសេចក្តីព្រាងច្បាប់នេះត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រី កាលពីខែកញ្ញា ឆ្នាំ២០២៣។

58. ការិយាល័យ OHCHR បានគាំទ្រដល់ក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ ក្នុងការបញ្ចប់ជាស្ថាពរនូវសេចក្តីវិភាគលើព្រះរាជក្រឹត្យ ស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ[32] ដែលបានធ្វើបទបង្ហាញជូនក្រសួងយុត្តិធម៌ និងដៃគូអភិវឌ្ឍន៍ ក្នុងខែមិថុនា ឆ្នាំ២០២៤។[33]

## ខ. យន្តការសិទ្ធិមនុស្សអន្តរជាតិ

59. ការិយាល័យ OHCHR បានបន្តផ្តល់មតិយោបល់ជូនកម្ពុជាស្តីពីការអនុវត្តអនុសាសន៍ ដែលផ្តល់ដោយយន្តការសិទ្ធិមនុស្សអន្តរជាតិ។ ការិយាល័យ OHCHR ក៏បានបន្តគាំទ្រដល់ការផ្សព្វផ្សាយអនុសាសន៍ទាំងនោះ និងបានបកប្រែឯកសារពាក់ព័ន្ធនានាពីយន្តការទាំងនេះ ជាភាសាខ្មែរ។

60. ក្នុងខែសីហា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានគាំទ្រដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងការផ្សព្វផ្សាយសេចក្តីសង្កេតសន្និដ្ឋាន របស់គណៈកម្មាធិការស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍[34] ដល់មន្ត្រីរាជការ និងមន្ត្រីរាជការស៊ីវិល ចំនួន ៣៥១នាក់ (ស្ត្រី ៩២នាក់ និងប្រុស ២៥៩នាក់) នៅខេត្តស្វាយរៀង និងខេត្តព្រៃវែង។ ក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ការិយាល័យ OHCHR និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិអំពីសេចក្តីសង្កេតសន្និដ្ឋាន របស់គណៈកម្មាធិការស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ[35] ដែលមានអ្នកចូលរួមសរុបចំនួន ៩៦ នាក់ (ស្ត្រី ២១ នាក់ និងបុរស ៧៥ នាក់) មកពីស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ។

61. នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៤ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តលទ្ធផលនៃ ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ របស់កម្ពុជា ក្នុងជុំទី៤។ កម្ពុជាបានទទួលអនុសាសន៍ចំនួន ២៧៥ ដែលក្នុងនោះ កម្ពុជាទទួលយកអនុសាសន៍ចំនួន ២៤៣ និងកត់សម្គាល់ចំនួន ៣២។ ការិយាល័យ OHCHR បានបកប្រែឯកសារ

[32] សូមមើល https://nadr.gov.kh/kh/library (ជាភាសាខ្មែរ)។

[33] A/HRC/57/78 កថាខណ្ឌ ៥១។

[34] CERD/C/KHM/CO/14-17 ។

[35] CED/C/KHM/CO/1

នេះជាភាសាខ្មែរ។[36] ក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ការិយាល័យ OHCHR បានគាំទ្រមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា រៀបចំសិក្ខាសាលាមួយ ដែលមានអ្នកចូលរួមចំនួន ៧៧ នាក់ (ស្ត្រី ៣០ នាក់ បុរស ៤២ នាក់ និងអ្នកមានយេនឌ័រចម្រុះ ចំនួន ៥ នាក់) មកពីស្ថាប័នចំនួន ៦០ ដើម្បីផ្សព្វផ្សាយអនុសាសន៍ទាំងនេះ ជូនដល់សង្គមស៊ីវិល និងផ្តល់ព័ត៌មានដើម្បីឱ្យពួកគេអាចគាំទ្ររដ្ឋាភិបាលក្នុងការអនុវត្តអនុសាសន៍។ ក្នុងខែមីនា ឆ្នាំ២០២៥ ការិយាល័យ OHCHR និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការផ្សព្វផ្សាយ និងតាមដានចំពោះការពិនិត្យឡើងវិញជាសកលតាមកាលកំណត់នេះ ដែលមានអ្នកចូលរួមសរុបចំនួន ១៤៥ នាក់ (ស្ត្រី ៤៩ នាក់ បុរស ៩៥ នាក់ និងអ្នកមានយេនឌ័រចម្រុះ ម្នាក់) មកពីស្ថាប័នរដ្ឋាភិបាល សភា សង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេស ដើម្បីផ្តួចផ្តើមបង្កើតផែនការអនុវត្តអនុសាសន៍មួយ តាមរយៈដំណើរការពិគ្រោះយោបល់។ ការិយាល័យ OHCHR បន្តធ្វើការជាមួយភាគីពាក់ព័ន្ធថ្នាក់ជាតិ ដើម្បីគាំទ្រការតាមដានការអនុវត្តអនុសាសន៍ នៃការពិនិត្យឡើងវិញជាសាកលតាមកាលកំណត់។

62. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានធ្វើទស្សនកិច្ចផ្លូវការមកប្រទេសកម្ពុជា ក្នុងខែកក្កដា ឆ្នាំ២០២៤។[37] របាយការណ៍ប្រចាំឆ្នាំរបស់គាត់ត្រូវបានបង្ហាញក្នុងសម័យប្រជុំលើកទី ៥៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[38]

63. ការិយាល័យ OHCHR បានសហការជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីពង្រឹងតួនាទីរបស់គណៈកម្មាធិការនេះ ឱ្យក្លាយជាយន្តការជាតិសម្រាប់ការអនុវត្ត ការរាយការណ៍ និងការតាមដានបន្ត។ ការិយាល័យ OHCHR បានផ្តល់យោបល់អំពីការអនុវត្តល្អៗ និងឧបករណ៍នានា ដើម្បីរៀបចំផែនការ និងតាមដានការអនុវត្តអនុសាសន៍ពីយន្តការសិទ្ធិមនុស្សអន្តរជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## គ. ការបញ្ជ្រាបសិទ្ធិមនុស្សតាមរយៈក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ

64. ការិយាល័យ OHCHR បានបន្តដឹកនាំកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ជ្រាបសិទ្ធិមនុស្សតាមរយៈការចូលរួមជាមួយក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ។ ការិយាល័យ OHCHR បានផ្តល់ការណែនាំបច្ចេកទេស ស្តីពីការដាក់បញ្ចូលគោលការណ៍សិទ្ធិមនុស្សទៅក្នុងក្របខណ្ឌកម្មវិធីជាតិ និងទៅក្នុងការអនុវត្តក្របខណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ សម្រាប់កម្ពុជា ឆ្នាំ ២០២៤-២០២៨។[39] ក្នុងនាមជាសហប្រធាននៃក្រុមលទ្ធផលទី ៤ ស្តីពីបរិវត្តកម្មសង្គម ជាមួយអង្គការ UNESCO ការិយាល័យ OHCHR បានសម្របសម្រួលភាពជាដៃគូយុទ្ធសាស្ត្រ ក្នុងចំណោមស្ថាប័នរបស់អង្គការសហប្រជាជាតិ និងជាមួយរដ្ឋាភិបាល ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស គណនេយ្យភាព ការចូលរួមរបស់ពលរដ្ឋ និងបរិយាបន្ន។ ដូចបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍លទ្ធផលប្រចាំឆ្នាំ ២០២៤ [40] កិច្ចខិតខំប្រឹងប្រែងរួមគ្នាទាំងនេះ បានចូលរួមចំណែកដល់វឌ្ឍនភាពឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការចាកចេញរបស់កម្ពុជាពីប្រទេសដែលមានការអភិវឌ្ឍតិចតួច។

# VII. គណនេយ្យភាព និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌

## ក. ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

---

[36] សូមមើល https://cambodia.un.org/en/node/267873 ។

[37] សូមមើល www.ohchr.org/en/press-releases/2024/07/cambodia-national-action-plan-indigenous-rightsamong-measures-needed ។

[38] A/HRC/57/82 ។

[39] សូមមើល https://unsdg.un.org/sites/default/files/2023-11/Cambodia_Cooperation_Framework_2024-2028.pdf ។

[40] សូមមើល https://cambodia.un.org/sites/default/files/2025-04/ARR2024_Cambodia_Final.pdf ។

65. កម្ពុជានៅតែបន្តជាប្រទេសប្រភព និងគោលដៅនៃអំពើជួញដូរមនុស្ស។ ទោះបីជារដ្ឋាភិបាលបានចាត់វិធានការដើម្បីដោះស្រាយអំពើជួញដូរនេះយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមនៅតែកើតមាន។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ស្ថាប័នអង្គការសហប្រជាជាតិ បានបន្តទទួលសំណើសុំជួយសង្គ្រោះពីជនជាតិនៃប្រទេសទីបី ដោយអះអាងថាពួកគេត្រូវបានគេជួញដូរ និងឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិត ក្នុងខេត្តកណ្តាល ក្រុងប៉ោយប៉ែត ខេត្តកំពត ខេត្តកោះកុង រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង។ ក្នុងខែមីនា ឆ្នាំ២០២៥ អ្នកកាន់អាណត្តិនីតិវិធីពិសេសមួយចំនួនបានផ្ញើលិខិតទំនាក់ទំនងទៅរដ្ឋាភិបាលពាក់ព័ន្ធនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស នៅក្នុងមជ្ឈមណ្ឌលឆបោកនៅអាស៊ីអាគ្នេយ៍។[41]

66. នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ឱ្យដំណើរការផែនការយុទ្ធសាស្ត្រថ្នាក់ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) ។[42] ផែនការនេះ មានយុទ្ធសាស្ត្រចំនួនបួន រួមមានវិធានការបង្ការទប់ស្កាត់ ការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ការការពារជនរងគ្រោះ ព្រមទាំងការអនុវត្តច្បាប់ និងគោលនយោបាយនានា។

67. ក្នុងខែតុលា ឆ្នាំ២០២៤ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអនុវត្តសេចក្តីណែនាំមួយស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាដើម្បីការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដោយបានបង្កើតសេចក្តីណែនាំនោះជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍។

## ខ. លក្ខខណ្ឌនៃការឃុំខ្លួន

68. យោងតាមទិន្នន័យពីអគ្គនាយកដ្ឋានពន្ធនាគារ បានឱ្យដឹងថា គិតត្រឹមខែឧសភា ឆ្នាំ២០២៥ ចំនួនអ្នកជាប់ពន្ធនាគារបានកើនឡើងដល់ ៥៦ ៨៦៩នាក់ (ស្ត្រី ៣ ៣៣១ នាក់ បុរស ៤៩ ៣១២ នាក់ កុមារី ១៤៣ នាក់ និងកុមារា ៤ ០៨៣ នាក់) មានកំណើន ២២ ភាគរយ បើធៀបនឹងខែឧសភា ឆ្នាំ២០២៤ ។ ចំនួនអនីតិជន ដែលបានជាប់ឃុំក្នុងខែឧសភា ឆ្នាំ២០២៥ បានកើនឡើង ៥៣ ភាគរយ បើធៀបទៅនឹងចំនួនអនីតិជនជាប់ឃុំចំនួន ២ ៧៦០ នាក់ (កុមារា ២ ៦៥៧ នាក់ និងកុមារី ១០៣ នាក់) ក្នុងខែឧសភា ឆ្នាំ២០២៤ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គេសង្កេតឃើញចំនួនអ្នកជាប់ពន្ធនាគារមានការកើនឡើងជាលំដាប់ ហើយអាជ្ញាធរពន្ធនាគារបានព្យាករណ៍ថា ការកើនឡើងនេះអាចនឹងឈានដល់តួលេខ ៦០ ០០០ នាក់ នៅចុងឆ្នាំ ២០២៥ ។[43] ចំនួនអ្នកជាប់ឃុំបណ្តោះអាសន្នរង់ចាំការជំនុំជម្រះក្តី នៅតែមានកម្រិតខ្ពស់ ជាមធ្យមប្រហែល ៣០ ភាគរយ នៃចំនួនអ្នកជាប់ពន្ធនាគារសរុប។

69. ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ការិយាល័យ OHCHR បានចុះទៅពិនិត្យពន្ធនាគារ ១១ កន្លែង ចំនួន ២៦លើក ដើម្បីពិនិត្យ លក្ខខណ្ឌនៃការឃុំខ្លួប។ ការិយាល័យ OHCHR បានសម្ភាសន៍អ្នកជាប់ឃុំ អតីតអ្នកជាប់ឃុំ និងអាជ្ញាធរពន្ធនាគារ ដែលពួកគេទាំងអស់បានសុទ្ធតែបានកត់សម្គាល់ថាភាពចង្អៀតណែនជាបញ្ហាប្រឈមដ៏ធំបំផុតមួយ ដែលប៉ះពាល់ដល់ការទទួលបានសេវាសំខាន់ៗ និងប៉ះពាល់ដល់លក្ខខណ្ឌនៃការឃុំខ្លួនប្រកបដោយសេចក្តីថ្លៃថ្នូរផងដែរ។

70. នៅក្នុងពន្ធនាគារជាច្រើន អ្នកជាប់ឃុំបានរាយការណ៍ថា កន្លែងគេងមានសភាពតូចចង្អៀតខ្លាំង។ នៅក្នុងពន្ធនាគារដែលមានភាពចង្អៀតណែនខ្លាំង ដូចជាពន្ធនាគារខេត្តកណ្តាល ម៉ោងចេញមកខាងក្រៅប្រចាំថ្ងៃសម្រាប់អ្នកជាប់ឃុំ ត្រូវបានកំណត់ត្រឹមតែ ៥០ នាទីប៉ុណ្ណោះ (ពេលព្រឹក ៣០ នាទី និងពេលរសៀល ២០

---

41 សូមមើលលិខិតទំនាក់ទំនង KHM 1/2025 ។

42 សូមមើល https://download.ncct.gov.kh/plans/ncct-action-plan-2024-2028-en.pdf ។

43 ការិយាល័យ OHCHR ជួបជាមួយតំណាងនៃអគ្គនាយកដ្ឋានពន្ធនាគារ កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤។

នាទី)។ មានការខ្វះខាតចំនួនបង្គន់ដែលអ្នកជាប់ឃុំប្រើប្រាស់ ដោយមានការរាយការណ៍ថា បង្គន់មួយសម្រាប់អ្នកជាប់ឃុំចំនួន ៤០ នាក់ ហើយក្នុងករណីមួយចំនួននាំឱ្យមានការរង់ចាំយូរ និងខ្វះអនាម័យថែមទៀត។

71. ដើម្បីបង្កើនទីធ្លាសម្រាប់ប្រើប្រាស់ ទីកន្លែងសម្រាប់សកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈ និងអគារបុគ្គលិកមួយចំនួន ត្រូវបានកែលម្អឡើងវិញ និងធ្វើជាបន្ទប់ឃុំឃាំង ជាហេតុនាំឱ្យបាត់បង់ឱកាសសម្រាប់ការអប់រំកែប្រែ និងស្តារនីតិសម្បទាសង្គម។ អាជ្ញាធរពន្ធនាគារក៏បានផ្ទេរអ្នកជាប់ឃុំពីកន្លែងតូចចង្អៀត ទៅកាន់ទីកន្លែងមានអ្នកជាប់ឃុំតិចផងដែរ។ ឧទាហរណ៍ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ ទណ្ឌិតជិត ២០០នាក់ ត្រូវបានផ្ទេរពីពន្ធនាគារខេត្តកណ្តាល ទៅកាន់មណ្ឌលអប់រំកែប្រែទី៤ ក្នុងខេត្តពោធិ៍សាត់។ ទោះបីជាវិធានការបែបនេះជួយសម្រាលដល់ភាពចង្អៀតណែនយ៉ាងណាក៏ដោយ ក៏វិធានទាំងនេះ នាំមកនូវបញ្ហាប្រឈមថ្មីៗដល់អ្នកជាប់ឃុំ ជាពិសេសនៅពេលត្រូវបានផ្ទេរទៅកាន់ទីតាំងដែលអាចជាបញ្ហាប្រឈមសម្រាប់ក្រុមគ្រួសារ និងមេធាវីរបស់ពួកគេ ក្នុងការធ្វើដំណើរទៅកាន់ទីនោះ។

72. ភាពចង្អៀតណែនធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរសម្រាប់អ្នកជាប់ឃុំដែលងាយរងគ្រោះ ដូចជាកុមារដែលបានជាប់ឃុំជាមួយម្តាយរបស់ពួកគេ ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ និងជនមានពិការភាពជាដើម។ ស្ត្រីជាច្រើននាក់ដែលបានជាប់ឃុំ នៅមណ្ឌលអប់រំកែប្រែទី២ បាននិយាយក្នុងអំឡុងពេលសម្ភាសន៍ថា ផលិតផលថែរក្សាអនាម័យ ជាពិសេស សំឡីអនាម័យ នៅពុំទាន់គ្រប់គ្រាន់ ហើយលើកឡើងទៀតថា ពួកគេត្រូវពឹងលើសមាជិកគ្រួសារ ឱ្យផ្ញើរបស់របរ ឬសាច់ប្រាក់ ដើម្បីទិញរបស់របរទាំងនោះនៅក្នុងពន្ធនាគារ។ ទាំងពន្ធនាគារខេត្តកណ្តាល និងមណ្ឌលអប់រំកែប្រែទី២ មិនមានទីធ្លាគ្រប់គ្រាន់សម្រាប់ឱ្យម្តាយបំបៅកូនដោយទឹកដោះ និងងូតទឹកឱ្យកូនៗរបស់ពួកគេជាលក្ខណៈឯកជនបានទេ។

73. នៅក្នុងពន្ធនាគារជាច្រើនដែលត្រូវបានចុះពិនិត្យ ការទទួលបានការថែទាំសុខភាព គឺជាបញ្ហាប្រឈមមួយ។ ស្ថានភាពចង្អៀតណែន ត្រូវបានគេរាយការណ៍ថាបណ្តាលឱ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រមិនបានគ្រប់គ្រាន់សម្រាប់អ្នកជាប់ឃុំ។ នៅតាមទីតាំងមួយចំនួន មានការកំណត់ឱ្យអ្នកជាប់ឃុំចំនួន ត្រឹមតែ ១០នាក់ប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យទទួលសេវានៅប៉ុស្តិ៍សុខភាពក្នុងមួយថ្ងៃ។ ការិយាល័យ OHCHR បានទទួលរបាយការណ៍ថា ក្នុងករណីខ្លះ អ្នកជាប់ឃុំចាំបាច់ត្រូវទទួលការអនុញ្ញាតពីប្រធានពន្ធនាគារ និងឆ្មាំពន្ធនាគារ ដើម្បីអាចទៅទទួលសេវាពីប៉ុស្តិ៍សុខភាព។

74. ការិយាល័យ OHCHR មានការព្រួយបារម្ភយ៉ាងខ្លាំង អំពីរបាយការណ៍នៃការកើតមានអំពើពុករលួយនៅតាមទីកន្លែងឃុំឃាំងមួយចំនួន។ ការិយាល័យ OHCHR បានទទួលរបាយការណ៍ថា ប្រធានបន្ទប់មួយចំនួន ដែលត្រូវបានចាត់តាំងដោយអាជ្ញាធរពន្ធនាគារដើម្បីឱ្យរាយការណ៍អំពីស្ថានភាពនៅក្នុងបន្ទប់ឃុំឃាំងរបស់ពួកគេ បានទាមទារឱ្យអ្នកជាប់ឃុំបង់ប្រាក់ជាថ្នូរនឹងការទទួលបានកន្លែងគេងបន្ថែម។ របាយការណ៍ផ្សេងទៀតបានបង្ហាញថា អ្នកជាប់ឃុំត្រូវបង់ប្រាក់ឱ្យអាជ្ញាធរពន្ធនាគារ សម្រាប់ការដឹកជញ្ជូនទៅកាន់តុលាការ ចំណែកអាហារ និងរបស់របរផ្សេងទៀតដែលលក់ក្នុងពន្ធនាគារច្រើនតែមានតម្លៃថ្លៃជាងទីផ្សារពីរ ឬបីដង។ លើសពីនេះ សមាជិកគ្រួសារបានបញ្ជាក់ថា ពួកគេត្រូវបានគេស្នើសុំឱ្យបង់ប្រាក់ចន្លោះពី ២,៥០ ដុល្លារ ទៅ ៥ ដុល្លារ ដើម្បីចូលសួរសុខទុក្ខអ្នកជាប់ឃុំ ដែលនេះផ្ទុយនឹងច្បាប់ជាតិ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

## គ. ជំនួយផ្នែកច្បាប់

75. ការិយាល័យ OHCHR បានសង្កេតឃើញបញ្ហាប្រឈមរបស់ជនជាប់ឃុំក្នុងការទទួលបានជំនួយផ្នែកច្បាប់ ហើយក្នុងករណីខ្លះបណ្តាលឱ្យមានការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន រង់ចាំការជំនុំជម្រះក្តីដោយមិនមានមេធាវីការពារក្តី។ ការិយាល័យ OHCHR បានចងក្រងសំណុំរឿងចំនួនប្រាំបី ដែលជនជាប់ចោទពុំមានតំណាងផ្លូវច្បាប់ ដោយសារខ្វះធនធានហិរញ្ញវត្ថុ ឬខ្វះព័ត៌មានអំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់។

76. ការិយាល័យ OHCHR បានបន្តគាំទ្រគំនិតផ្តួចផ្តើមជំនួយផ្នែកច្បាប់ រួមទាំងតាមរយៈការផ្តល់ហិរញ្ញប្បទានឥតសំណងជូនដល់អង្គការសង្គមស៊ីវិលចំនួនពីរផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាទាំងនេះ បានកំណត់បញ្ហាប្រឈមមួយចំនួន ដូចជាការលំបាកក្នុងការផ្តល់មូលនិធិ និងការធ្លាក់ចុះនៃចំនួនមេធាវីដែលអាចដោះស្រាយសំណុំរឿងពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស។ អ្នកការពារសិទ្ធិមនុស្សដែលត្រូវបានឃុំខ្លួនជាច្រើននាក់ បានរាយការណ៍ថាមេធាវីរបស់ពួកគេមិនអាចចុះសួរសុខទុក្ខពួកគេបានទេ ចាប់តាំងពីដើមឆ្នាំ២០២៥មក ដោយសារតែខ្វះថវិកា និងបានរាយការណ៍ដែរថា មេធាវីរបស់ពួកគេមិនដឹងពីស្ថានភាពនៃសំណុំរឿងរបស់ពួកគេទេ។

77. ក្នុងខែសីហា ឆ្នាំ២០២៤ តបតាមសំណើរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ការិយាល័យ OHCHR បានផ្តល់វគ្គបណ្តុះបណ្តាលមួយ ស្តីពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងការឃុំខ្លួនបណ្តោះអាសន្ន ដល់មេធាវីផ្តល់ជំនួយផ្នែកច្បាប់ដោយស្ម័គ្រចិត្ត និងបុគ្គលិករបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចំនួន ៣៥ នាក់ (ស្ត្រី ១១ នាក់ និងបុរស ២៤ នាក់) ។

## VIII. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

**78. អគ្គលេខាធិការ ទទួលស្គាល់នូវការចូលរួមជាវិជ្ជមានរបស់រដ្ឋាភិបាល ជាមួយការិយាល័យ OHCHR និងប្រព័ន្ធអង្គការសហប្រជាជាតិ និងគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ការិយាល័យ OHCHR ក្នុងការគាំទ្រដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់សិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា។ អគ្គលេខាធិការ នៅតែមានការព្រួយបារម្ភចំពោះការរឹតត្បិតលំហពលរដ្ឋ និងសិទ្ធិមនុស្ស រួមទាំងសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ សេរីភាពខាងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងសមាគម ។**

**79. អគ្គលេខាធិការ អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមឱ្យ៖**

**(ក) បែងចែកធនធានដែលមានជាអតិបរមា ដើម្បីសម្រេចបាននូវវឌ្ឍនភាពនៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សម្រាប់ទាំងអស់គ្នា រួមទាំងតាមរយៈការបង្កើនការចំណាយសាធារណៈឱ្យបានច្រើន នៅក្នុងវិស័យសន្តិសុខសង្គម ការថែទាំសុខភាព និងការអប់រំ ក្នុងគោលបំណងកាត់បន្ថយវិសមភាព។**

**(ខ) ធានាថាថវិកាជាតិត្រូវបានរៀបចំ និងអនុវត្តប្រកបដោយតម្លាភាព និងបរិយាបន្ន តាមរយៈការបញ្ចេញទិន្នន័យដែលមានការបែងចែកអំពីការផ្តល់ថវិកា និងការចំណាយជាក់ស្តែង តាមរយៈក្រសួងកម្មវិធី ព្រមទាំងការធ្វើចំណាត់ក្រុមសេដ្ឋកិច្ច និងមុខងារ ក៏ដូចជាតាមរយៈការចូលរួមយ៉ាងសកម្មពីសាធារណៈនៅក្នុងដំណើរការរៀបចំ និងអនុវត្តថវិកា។**

**(គ) ធានាផងដែរថា គោលនយោបាយ និងច្បាប់គាំពារសង្គម អនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងគោលការណ៍នៃភាពសមស្រប សមរម្យ ជាសកល តម្លាភាព និងគ្មានការរើសអើង ហើយមានលក្ខណៈឆ្លើយតបទៅនឹងយេនឌ័រ ដើម្បីផ្តល់កិច្ចគាំពារសង្គមជាសកល សម្រាប់ទាំងអស់គ្នា ជាពិសេសកម្មករបម្រើការងារនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។**

**(ឃ) ធានាបន្ថែមទៀតថា ការបែងចែកថវិកាសម្រាប់វិស័យសុខាភិបាល និងវិស័យអប់រំ នៅតែបន្តសមាមាត្រនឹងកំណើនផលិតផលក្នុងស្រុកសរុប ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងការសម្រេចបាននូវវឌ្ឍនភាពនៃសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា។**

**(ង) វិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីកំណត់ ហាមឃាត់ និងដាក់ទោសទណ្ឌរាល់គ្រប់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ អនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។**

(ច) ផ្តល់ភាពស្របច្បាប់ដល់អាពាហ៍ពិពាហ៍ភេទដូចគ្នា និងការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ស្របតាមអនុសាសន៍ដែលបានទទួលយក ក្នុងយន្តការការពិនិត្យឡើងវិញជាសកលតាមកាលកំណត់។

(ឆ) ធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនូវការទទួលបានការចុះសំបុត្រកំណើត តាមរយៈវិធានការជាក់ស្តែង និងស្របតាមគោលដៅ រួមទាំងនីតិវិធីរដ្ឋបាលដែលមានយុត្តិធម៌ និងបរិយាបន្ន ការផ្សព្វផ្សាយដល់ប្រជាជនដែលជួបប្រទះការលំបាក ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ កិច្ចសហការអន្តរក្រសួង និងគោលការណ៍ណែនាំ ព្រមទាំងការកសាងសមត្ថភាពដល់មន្ត្រីអត្រានុកូលដ្ឋាននៅមូលដ្ឋាន។

(ជ) បញ្ចប់ជាស្ថាពរ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារសិទ្ធិជនពិការ អនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងបញ្ជូនរបាយការណ៍ដំបូងទៅគណៈកម្មាធិការសិទ្ធិជនពិការ ដោយមិនពន្យារពេល។

(ឈ) ពង្រឹងលំហពលរដ្ឋ និងប្រជាធិបតេយ្យ ដោយការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់វណ្ណៈ រួមទាំងសេរីភាពខាងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងសមាគម កំណែទម្រង់ច្បាប់ និងគោលនយោបាយ ដើម្បីធានាបាននូវការចូលរួមប្រកបដោយប្រសិទ្ធភាព និងប្រកបដោយអត្ថន័យ ដោះលែងជាបន្ទាន់អ្នកដែលត្រូវបានឃុំខ្លួនតាមទំនើងចិត្ត ចំពោះការអនុវត្តសិទ្ធិមនុស្សរបស់ពួកគេ ព្រមទាំងបញ្ឈប់ និងទប់ស្កាត់ការបំភិតបំភ័យ និងការបៀតបៀនអ្នកនយោបាយ សកម្មជនការពារសិទ្ធិមនុស្ស និងសង្គមស៊ីវិល។

(ញ) អនុម័តច្បាប់ស្តីពីការបង្កើតគណៈកម្មាការជាតិសិទ្ធិមនុស្ស និងគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងការធានានូវឯករាជ្យភាពនៃមុខងារ និងប្រតិបត្តិការរបស់ស្ថាប័នទាំងពីរ។

(ដ) បន្តចូលរួមជាមួយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងធានាការអនុវត្តអនុសាសន៍របស់យន្តការទាំងនោះ រួមទាំងអនុសាសន៍របស់ស្ថាប័នសន្ធិសញ្ញា នីតិវិធីពិសេស និងការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ហើយធានាថាភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសសង្គមស៊ីវិល ត្រូវបានពិគ្រោះយោបល់ និងអាចចូលរួមនៅក្នុងដំណើរការទាំងនេះប្រកបដោយប្រសិទ្ធភាព និងអត្ថន័យ ។

(ឋ) ចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីដោះស្រាយបញ្ហាឫសគល់នៃការជួញដូរមនុស្ស ស៊ើបអង្កេត និងកាត់ទោសអ្នកដែលទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព និងធានានូវគោលនយោបាយ និងកម្មវិធីស្តារនីតិសម្បទាផ្តោតលើជនរងគ្រោះ និងបញ្ហាយេនឌ័រ រួមទាំងតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងការធានាឱ្យបាននូវធនធានសមស្រប និងការសម្របសម្រួលក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ច។

(ឌ) កាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារ និងកែលម្អលក្ខខណ្ឌនៃការឃុំខ្លួនតាមរយៈការពង្រឹងវិធានការជំនួសឱ្យការឃុំឃាំង ការអនុម័តគោលនយោបាយជាតិសម្រាប់ជំនួយផ្លូវច្បាប់ ដែលត្រូវអនុវត្តដោយមានធនធានគ្រប់គ្រាន់ និងការកែលម្អការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ផងដែរ។